CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣១ ខែឧសភា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៨៦




## ពលរដ្ឋកម្ពុជាស្វាគមន៍វប្បធម៌សន្ទនាតែខ្លាចវប្បធម៌នេះមានអាយុខ្លី


### សេចក្តីជូនដំណឹង

គណៈកម្មការសម្រាប់កិច្ចការមរណសាក្សីនៅកម្ពុជា សូមជម្រាបដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ ឲ្យបានជ្រាបថា បច្ចុប្បន្នគណៈកម្មការយើងខ្ញុំកំពុងធ្វើ និង ចងក្រងសំណុំឯកសារអំពីមរណសាក្សី នៃព្រះសហគមន៍កាតូលិក។ សូមបងប្អូនសហការផ្តល់ជាព័ត៌មានមកកាន់ ៖ **លោក រឿង ឆ័ត្រសិរី** ( Fr. RoeungChatsirey )។

**Tel: 077 800 211 / 096 34 22 144**

អ៊ីម៉ែល ៖ martyrscambodia@gmail.com | ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# សារលិខិតលោកអភិបាល

CARITAS CHRISTI URGET NOS

ភ្នំពេញ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៥គោរពជូន ឯកឧត្តម ប៉ូល ស៊ីមីក

អភិបាលព្រះសហគមន៍កាតូលិកនៅនេប៉ាល់ និងប្រជាជនទាំងអស់!

លោកអភិបាលជាទីរាប់អាន!

យើងទើបតែបានជួបគ្នានៅក្នុងឱកាសនៃទិវាយុវជនអាស៊ី!

ស្រាប់តែពេលនេះ ខ្ញុំបានទទួលដំណឹងអាក្រក់បំផុត អំពីសោកនាដកម្ម ដែលមនុស្សជាច្រើនបាត់បង់អាយុជីវិត ហើយចំនួនមានការកើនឡើងជារៀងរាល់ថ្ងៃ ដែលបង្កឡើងដោយការរញ្ជួយដី វាបានបំផ្លាញទីក្រុងកាត្មាន់ឌូ និងភូមិតូចៗជាច្រើនទៀតនៅក្នុងប្រទេសនេប៉ាល់របស់លោកអភិបាល។

ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជារួមជាមួយនិងខ្ញុំសូមសម្តែងសាមគ្គីភាពដ៏ស្មោះអស់ពីដួងចិត្ត ចំពោះប្រជាជននេប៉ាល់ និងសម្តែងទុក្ខដ៏ក្រៀមក្រំរបស់យើង ចំពោះសោកនាដកម្មយ៉ាងរន្ធត់នេះ។

ខ្ញុំសូមអង្វរព្រះជាម្ចាស់ដ៏មានតេជានុភាពសព្វប្រការនៃយើង សូមព្រះអង្គប្រទានសេចក្តីក្លាហាន ការសម្រាលទុក្ខសោក និងសេចក្តីសង្ឃឹមដល់បងប្អូនគ្រប់គ្នា ដែលរងគ្រោះដោយសារគ្រោះមហន្តរាយដ៏រន្ធត់យ៉ាងនេះ។

ហេតុនេះ ខ្ញុំសូមសម្តែងសមានចិត្តរបស់ខ្ញុំ ភាពជិតស្និទ្ធរបស់ខ្ញុំជាមួយបងប្អូនទាំងអស់និងការអធិដ្ឋានដ៏កក់ក្តៅបំផុតរបស់ខ្ញុំ នៅក្នុងពេលដ៏លំបាកយ៉ាងក្រៃលែង។

សូមលោកអភិបាលទទួលសេចក្តីគោរពដ៏ជ្រាលជ្រៅពីខ្ញុំក្នុងអង្គព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។

ព្រះសហគមន៍កាតូលិកភ្នំពេញ នៅប្រទេសកម្ពុជា

APOSTOLIC VICARIATE PHNOM PENH







© Reuters/N. Chitrakar

Radio Veritas Asia
Crossing Borders, Sharing Christ

**វិទ្យុវ៉ារីតាស់អាស៊ី (RVA) ផ្សាយតាមរលកធាតុអាកាសខ្លី (SW)**
**ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :**

ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវ៉ារីតាស់អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើនទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានា ពីព្រះសហគមន៍កាតូលិកកម្ពុជា។

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

**Tel/Fax** : (855) 23 224 120

**Email** : csccambodia@gmail.com / **Website** : www.catholiccambodia.org

**ចាងហ្វាង : លោក លី សុវណ្ណា**

Licence ៣៧០ ពម.ប្រក./ ២៤-មិថុនា-២០១០

# តើពេលណាទើបក្រមសីលធម៌គ្រូពេទ្យបានប្រសើរឡើង ?



កន្លងទៅថ្មីៗនេះ គឺពិតជារន្ធត់ណាស់ នៅពេលដែលមានអ្នកជំងឺម្នាក់ដេករង់ចាំរហូតដល់ស្លាប់ ពេលទៅដល់មន្ទីរពេទ្យហើយនោះ ព្រោះតែគ្មានលុយនោះ នៅឯខេត្តព្រះវិហារ។កន្លងមកយើងតែងទទួលបានពត៌មានដែលចុះផ្សាយតាមទំព័រសារព័ត៌មាននានា និង តាមបណ្តាញផ្សព្វផ្សាយសង្គម Facebook ជាបន្តបន្ទាប់ នូវទង្វើអមនុស្សធម៌ របស់គ្រូពេទ្យបែបនេះ។ ស្ត្រីឆ្លងទន្លេខ្វះលុយគឺមិនមាន គ្រូពេទ្យយកចិត្តទុកដាក់ទុករហូតដល់ស្លាប់ក៏មាន។ គ្មានលុយកុំមកនិយាយជាមួយគ្រូពេទ្យរដ្ឋ ។ ពាក្យសំដីចោលដឹងទាំងដង។ ទាំងនេះគឺសុទ្ធតែយើងបានឮចេញពីមាត់របស់ពលរដ្ឋ ដែលបានទទួលសេវាកម្មព្យាបាលនៅមន្ទីរពេទ្យរដ្ឋ។ គ្រូពេទ្យទទួលការអប់រំ គឺដើម្បីសង្គ្រោះជីវិតមនុស្ស គេមិនប្រកាន់អ្វីឡើយ ទោះបីក្នុងពេលមានសង្គ្រាម គឺគេព្យាបាលមិនរើសមុខទេ បូករួមទាំងខ្មាំងសត្រូវរបស់ខ្លួនផងដែរ។

សង្គមដែលស៊ីវិល័យ សង្គមដែលឲ្យតម្លៃលើ អំណាចទឹកប្រាក់ជាធំ អំណាចលើសម្ភារៈនិយម បានផ្លាស់ប្តូរចរិកលក្ខណៈមនុស្សទាំងស្រុងតែម្តង ភ្លេចនូវអ្វីដែលជាគុណធម៌ទាំងឡាយ ដែលខ្លួនបានរៀនសូត្រក្នុងមុខងារជាអ្នកសង្គ្រោះជីវិត។ យើងអាចនិយាយបានថា បាត់បង់សារជាតិជាមនុស្សព្រោះតែលុយ។

សម្តេចប្រមុខរាជរដ្ឋាភិបាល ក៏ធ្លាប់បានអំពាវនាវរួចហើយដែរ ចំពោះគ្រូពេទ្យទាំងអស់ "សូមឲ្យយកចិត្តទុកដាក់ ព្យាបាលអ្នកជំងឺសិនទៅ មុនគិតអំពីលុយ"។ តែការអំពាវនាវនេះ ហាក់បីដូចជាគ្មានប្រសិទ្ធភាពនោះឡើយ។ ក្រសួងសុខាភិបាលរបស់ជាតិទាំងមូល ហាក់ដូចជាគ្មានចំណាត់ការជាដុំកំភួនអ្វីដែរ។

ជីវិតមនុស្សមានតម្លៃណាស់ មិនស្មើនឹងតម្លៃទឹកប្រាក់ទេឬ? កុំភ្លេចថា គ្រូពេទ្យរដ្ឋទាំងអស់ ទទួលប្រាក់ខែពីរដ្ឋ ដែលជាលុយពលរដ្ឋបង់ពន្ធរាល់ថ្ងៃ។តើឲ្យពលរដ្ឋក្រីក្រសង្ឃឹមអ្វីពីសេវាកម្មសាធារណៈរបស់រដ្ឋនោះ ? ប្រហែលនេះជាមូលហេតុមួយ ដែលពលរដ្ឋសុខចិត្តដេកស្លាប់នៅផ្ទះ មិនទៅព្យាបាល នៅមន្ទីរពេទ្យរដ្ឋនោះឡើយបើគេគ្មានលុយ។ បើពលរដ្ឋអ្នកមានលុយល្មម គេទៅទទួលការព្យាបាលនៅប្រទេសជិតខាង ព្រោះគ្រូពេទ្យគេយកចិត្តទុកដាក់ និងមានក្រមសីលធម៌ល្អចំពោះអ្នកជំងឺ។

ប៉ុន្តែយើងខ្ញុំ ក៏សូមកោតសរសើរ និងទទួលស្គាល់ដែរថា គ្រូពេទ្យមួយចំនួនក៏បានខិតខំ យកចិត្តទុកដាក់យ៉ាងអស់ពីចិត្តរបស់ខ្លួន ក្នុងការព្យាបាលអ្នកជំងឺ។ គេមានក្រមសីលធម៌ល្អប្រសើរណាស់ចំពោះអ្នកជំងឺ ទាំងអ្នកមាន និងអ្នកក្រ។ មន្ទីរពេទ្យមួយចំនួន មណ្ឌលសុខភាពមួយចំនួន បានដើរតួនាទីយ៉ាងល្អប្រសើរហើយដែរក្នុងការបម្រើ និងផ្តល់សាវាព្យាបាលជូនប្រជាពលរដ្ឋរបស់ខ្លួន។ទោះជាយ៉ាងណាក្តី "ត្រីមួយកន្ត្រក់ស្អុយមួយ គឺស្អុយទាំងអស់"។

សរុបមក ក្រសួងសុខាភិបាលរបស់ជាតិ គួរតែមានវិធានយ៉ាងម៉ឺងម៉ាត់ ចំពោះទង្វើអសកម្ម ទង្វើអមនុស្សធម៌ ចរិកឫកពារមិនថ្លៃថ្នូររបស់ គ្រូពេទ្យមួយចំនួនទាំងនោះ ព្រោះថា បើនៅតែបណ្តែតបណ្តោយទៅទៀត វានាំឲ្យមានជំងឺមហារីកក្នុងសង្គមកាន់តែខ្លាំងឡើងៗ។ វានាំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ បាត់បង់តម្លៃនៃវិជ្ជាជីវៈជាគ្រូពេទ្យ។ បាត់បង់ចរិកពិតរបស់ខ្មែរ គឺខ្មែរជាមនុស្សរួសរាយរាក់ទាក់ ចេះជួយគ្នាទៅវិញទៅមក មិនអត្តានិយម។ វាក៏នឹងធ្វើឲ្យវិស័យសុខាភិបាលនេះ មានរូបភាពមិនល្អ គ្មានទំនុកចិត្តពីមហាជន។ វាក៏នឹងធ្វើឲ្យប៉ះពាល់ ដល់កិត្យានុភាពដ៏ប្រពៃរបស់រាជរដ្ឋាភិបាលផងដែរ៕

## ព័ត៌មានកាតូលិកអន្តរជាតិ .

# សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ៖

## សាសនាមិនគួរកំណត់ទៅមនសិការផ្ទាល់ខ្លួន

តាមវិទ្យុវាទីកង់ កាលពីពេលថ្មីៗកន្លងទៅនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា មនុស្សជាតិមិនគួរកំណត់សាសនាថា ជាមនសិការផ្ទាល់ខ្លួនឡើយ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា សាសនាគឺដាច់ខាតមិនមែនជាមនសិការ ផ្ទាល់ខ្លួនរបស់មនុស្សណាម្នាក់ឡើយ ប៉ុន្តែវាស្ថាប័នមួយដែលមានតួនាទីសំខាន់ នៅក្នុងការកសាងសង្គម។

ប្រភពដដែល បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍បែបនេះ នៅពេលដែលសម្តេចបានទទួល ជួបសាវនាការ ជាមួយនឹងលោក ស៊ើជីអូ ម៉ាតារ៉េឡា ជាប្រធានាធិបតី នៃប្រទេសអ៊ីតាលីតាំងពីលោកត្រូវបានជាប់ឆ្នោត កាលពីថ្ងៃទី ០៣ ខែកុម្ភៈ កន្លងទៅ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា នៅក្នុងចំណោមសាសនានានា ព្រះសហគមន៍កាតូលិក គឺកំពុងតែផ្តល់ដល់គ្រីស្តបរិស័ទនានា នូវដំណឹងល្អ និងកំពុងតែណែនាំឲ្យគ្រីស្តបរិស័ទ ទាំងអស់គ្នាយល់អំពីភាពចាំបាច់នៃសន្តិភាពភាពស្ងប់ស្ងាត់ មិត្តភាព និងទំនាក់ទំនងសហប្រតិបត្តិការ ។

សម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូ ក៏បានរំឭកលោកប្រធានាធិបតី នៃប្រទេសនេះ អំពីកិច្ចសហប្រតិបត្តិការរវាងបុរីវាទីកង់ និង អ៊ីតាលីផងដែរ៕



## សម្តេចប៉ាបអធិដ្ឋានសម្រាប់គ្រោះរញ្ជួយដីនៅនេប៉ាល់

វិទ្យុវាទីកង់ បានរាយការណ៍ថា កាល ពីថ្ងៃទី២៦ ខែ មេសា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានធ្វើការអធិដ្ឋានសម្រាប់ជនរងគ្រោះ នៅក្នុងគ្រោះរញ្ជួយដី ដែលកើតមានឡើងនៅក្នុងប្រទេសនេប៉ាល់។

គ្រោះរញ្ជួយដីនេះ គឺបានកើតឡើងនៅក្នុងប្រទេសនេះ នៅក្នុងវេលាថ្ងៃត្រង់ កាលពីថ្ងៃសៅរ៍សប្តាហ៍កន្លងទៅនៅក្នុងកំរិត ៧,៩ រ៉ិចទ័រ ។

គ្រោះរញ្ជួយដីនេះ បានបង្កគ្រោះមហន្តរាយធំជាងគេ នៅក្នុងសង្កាត់ដែលមានប្រជាពលរដ្ឋ រស់នៅច្រើនបំផុត នៅជ្រលងភ្នំនៃទីក្រុង កាឋ្មាន់ឌូ រដ្ឋធានីនៃប្រទេសមួយនេះ ។

តួលេខបឋមថា មានមនុស្សរាប់រយនាក់បានស្លាប់ និង របួស ។

គ្រោះរញ្ជួយដីនេះ ក៏បានផ្តួលសំណង់បុរាណអាយុ ១០០ ឆ្នាំមួយកន្លែង និង ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងផ្លូវថ្នល់ជាច្រើនកន្លែង ។

នៅក្នុងចំណោម អាគារដែលត្រូវបានបំផ្លាស សំណង់ប៉បដាហ៉ារដែលបានកសាង និងជួសជុលជាបន្តបន្ទាប់ ដោយរាជវង្សនេប៉ាល់ ដែលបានគ្រប់គ្រងប្រទេសនេះ តាំងពីឆ្នាំ ១៨០០មក ក៏ដួលរលំផងដែរ ហើយគេព្យាករណ៍ថា មនុស្សប្រមាណជា ៥០នាក់កំពុងតែជាប់នៅក្នុងសំណង់នោះ៕

# ស្ពានអ្នកលឿងសមិទ្ធិផលដ៏មានន័យសម្រាប់ពលរដ្ឋកម្ពុជា



*ស្ពានអ្នកលឿងដែលបានសម្ពោធនិងដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី ០៦ ខែមេសា ២០១៥។ រូបភាព: ???*

បើទោះបីជាទិដ្ឋភាពនៃការកកស្ទះ នៅតែបន្តកើតមាន នៅលើកំណាត់ផ្លូវជាតិលេខមួយ ជាពិសេសនៅត្រង់ស្ពានអ្នកលឿង កាលពីអំឡុងពេលចូលឆ្នាំថ្មីប្រពៃណីជាតិ ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាទូទៅនៅតែបង្ហាញអំពីសុទិដ្ឋិនិយមថា ស្ពានថ្មីនេះ នឹងជំរុញល្បឿន នៃការផ្លាស់ប្តូរកសិផលពាណិជ្ជកម្មនៅក្នុងតំបន់ និង អន្តរជាតិ ល្បឿននៃការធ្វើដំណើរ ក៏ដូចជាសកម្មភាព សង្គ្រោះបន្ទាន់ផ្សេងៗ របស់ប្រជាពលរដ្ឋកម្ពុជាទូទៅ ។

លោក សាញ់ ចំរើន ប្រជាពលរដ្ឋកម្ពុជានៅភ្នំពេញ បានមានប្រសាសន៍ នៅពេលដែលកកស្ទះ នៅគល់ស្ពានអ្នកលឿង កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៥ថា ស្ពាននេះប្រហែលជាកកស្ទះតែត្រឹមចូលឆ្នាំនេះទេ ដោយសារតែម្នាក់ៗ ទាំងលោកទាំងគេ គឺសម្រុកមកកាន់ទីនេះ ដោយសារតែចង់ស្គាល់ និង ចង់ឃើញទិដ្ឋភាពដ៏អស្ចារ្យ នៃស្ពានឆ្លងទន្លេវែងជាងគេនៅកម្ពុជា ។

លោកបានបញ្ជាក់ថា "ម៉ាឈប់សម្រាកចូលឆ្នាំ ប្រហែលជាជិតមួយសប្តាហ៍នេះ ខ្ញុំគិតថា ពលរដ្ឋកម្ពុជាភាគច្រើននៅភ្នំពេញ សុទ្ធតែតម្រង់ក្បាលឡានមកកាន់ទីនេះ ឥចឹងហើយបានជាវាកកស្ទះ"។

លោកបានបន្តទៀតថា តាមទិដ្ឋភាពជាក់ស្តែង ការកកស្ទះនេះមិនមែនដោយសារតែ ឡានវាច្រើនពេកនោះទាំងអស់ទេ កត្តាមនុស្សក៏ចូលរួមចំណែកដែរ ដូចជាការបើកបរខ្វះការគោរពច្បាប់ចរាចរណ៍ ដោយពេលឡើងស្ពានផ្លូវមានតែពីរគន្លង អ្នកបើកឡានឡើងដល់ទៅ ៤ ជួរ ហើយមិនតែប៉ុណ្ណោះទៀត អ្នកខ្លះ គឺបើកទៅដល់ស្ពានហើយ នាំគ្នាចតឡានចុះថតរូប ទិញនំចំណីនៅលើនោះថែមទៀតដូច្នេះហើយ បានជាមានការកកស្ទះ ។

លោកបានបញ្ជាក់ថា "សង្ឃឹមថា ចាប់ពីចូលឆ្នាំថ្មីចប់ទៅ ស្ពានភាពនឹងប្រសើរ ពលរដ្ឋនឹងយល់ដឹង ដោយសារស្ពាន មិនមែនជាកន្លែងចំណតទេ"។

លោកបានបន្តទៀតថា អាជ្ញាធរគួរគប្បីថែរក្សាសណ្តាប់ សន្តិសុខ និងសុវត្ថិភាពនៅកំណត់ស្ពាននេះ ឲ្យបានមាំទាំ ពីព្រោះថា ក្រៅពីជាសមិទ្ធផលថ្មីរបស់ប្រទេស ស្ពានអ្នកលឿងនេះក៏ជាការតភ្ជាប់ កំណាត់ផ្លូវជាតិលេខមួយ ពីត្រើយខាងលិចទៅត្រើយខាងកើត ដែលជាច្រកសម្រាប់ធានា ការធ្វើដំណើរ និងដឹកជញ្ជូនដ៏សំខាន់រវាងការផ្លាស់ប្តូរពាណិជ្ជកម្ម និង ទេសចរណ៍រវាងកម្ពុជា និង វៀតណាម ហើយក៏ជាផ្លូវ សង្គ្រោះបន្ទាន់មួយផងដែររបស់ប្រជាពលរដ្ឋកម្ពុជា ។

លោកបានបញ្ជាក់ថា "មួយថ្ងៃៗ កំណាត់ផ្លូវនេះ បម្រើការដឹកជញ្ជូនអ្នកជំងឺ មិនតិចនាក់ទេទៅស្វែងរកសេវាព្យាបាលនៅវៀតណាម រួមទាំងអ្នកជំងឺសង្គ្រោះបន្ទាន់ផងដែរ" ។

លោកស្រីឃិត សុផាវី ជាអ្នកដំណើរមួយរូបដែលធ្វើដំណើរទៅលេងស្រុកកំណើតនៅកំពង់ត្របែក ខេត្តស្វាយរៀងបានមានប្រសាសន៍ថា លោកស្រី និង ក្រុមគ្រួសារជាប់នៅក្នុងការកកស្ទះចរាចរណ៍នៅគល់ស្ពាននេះ ប្រហែលជា៣ម៉ោង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រសើរជាងកាលពីមិនទាន់មានស្ពានដែរ។ លោកស្រីបានបញ្ជាក់ថា "ឆ្នាំទៅខ្ញុំជាប់ការកកស្ទះរង់ចាំសាឡាងកន្លះថ្ងៃ ក្រោមកំដៅក្តៅហែង"។

លោកស្រី បានបន្តបញ្ជាក់ថា "បើទោះបីជាមានការកកស្ទះបន្តិច ប៉ុន្តែយើងមិនដែលបានឃើញ ស្ពានវែងខ្ពស់បែបនេះពីមុនមកទេ វាពិតជាអស្ចារ្យ នៅក្នុងអារម្មណ៍មែនទែន ទោះបីជាយើងបានឃើញ ទិដ្ឋភាពតាមដងផ្លូវនេះ ជាញឹកញាប់ក៏ដោយចុះ"។

លោកស្រីបានបន្តទៀតថា ពេលឆ្លងពីត្រើយ ខាងលិចមកដល់គល់ស្ពាន នៅត្រើយខាងកើត ហើយឈប់ឡានសម្លឹងទៅស្ពានវិញ គឺពិតជាមានអារម្មណ៍ថាអស្ចារ្យគួរឲ្យស្ញប់ស្ញែង ។

ខណៈដែលអ្នកដំណើរ ឆ្លងកាត់ស្ពាននេះ ភាគច្រើនសម្តែងអំពីមោទនភាពនឹងសមិទ្ធិផលថ្មីនេះ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋមួយចំនួន បាននិយាយទាំងទឹកមុខស្ងួតថា ពួកគេនៅពេលនេះមិនដឹងថារំពឹងទៅលើអ្វីនៅឡើយទេ ក្រោយពេលដែលកំណាត់ផ្លូវជាតិលេខមួយនេះ មានស្ពានអ្នកលឿងនេះ។

ពួកអ្នកសម្តែងនូវការ ព្រួយបារម្ភទាំងនេះ ភាគច្រើនគឺជាប្រជាពលរដ្ឋដែលមានមុខរបរលក់នំ លក់ភេសជ្ជៈ លក់កសិផលផ្សេងៗនៅលើសាឡាង។

អ្នកស្រី ចក់ សំអាត ជាអាជីវករទូលស្ករគ្រាប់ នំ និង ភេសជ្ជៈមួយរូបនៅសាឡាងអ្នកលឿង បានអះអាងថា ចាប់តាំងពីស្ពាននេះត្រូវអាជ្ញាធរបើកដាក់ឲ្យដំណើរការមក អ្នកស្រីនៅមិនទាន់មានមុខរបរអ្វីពិតប្រាកដនៅឡើយទេ។

អ្នកស្រី បានអះអាងថា ឥឡូវនេះគឺប្រាក់ចំណូលពឹងតែលើប្តី ដែលមានរបររត់ម៉ូតូឌុបម្នាក់ប៉ុណ្ណោះ ក្រោយពេលរបរប្រចាំថ្ងៃ បានប្រាក់ចំណូល ៤ ទៅ ១០ ម៉ឺនរៀល ត្រូវសម្រាកជាងកន្លះខែហើយចាប់ពីស្ពានសម្ពោធ។

អ្នកស្រី បានបញ្ជាក់ថា "ឥឡូវនេះមានអ្នកណាគេ ចូលទិញអីនៅអ្នកលឿងទៀត បើអ្នកដំណើរភាគច្រើនទៅផុតម៉ោផុត "។

លោកស្រីម្ចាស់ហាងបាយ មួយកន្លែង នៅកំពង់ចម្លងអ្នកលឿង បានអះអាងថា ហាងរបស់លោកស្រី ក៏ស្ងាត់ដែរ តាំងពីបើកសម្ពោធស្ពាននេះមកដល់ចូលឆ្នាំ។

លោកស្រី បានបញ្ជាក់ថា "អ្នកដំណើរ គេភ្លេចពួកយើងអស់ហើយពេលនេះ ឆ្នាំមុនៗពេលអត់ស្ពានហើយមានការកកស្ទះគេចូលញ៉ាំនេះញ៉ាំនោះ យ៉ាងហោចណាស់ ក៏អស់គោជល់ បាកាសអីមួយកំប៉ុងដែរប៉ុន្តែពេលនេះ គ្រាន់តែបត់ឡានចូលអើតបន្តិចសឹងតែគ្មាន"។

ស្ពានអ្នកលឿង ត្រូវបានគេដឹងថាគឺជាស្ពានដែលមានប្រវែង ២.២១៥ម បើបូកជាមួយនឹងផ្លូវ គឺមានបណ្តោយសរុប ៣.១០០ម៉ែត្រ ដោយចំណាយថវិការសាងសង់ អស់ប្រមាណជា ១២៧លានដុល្លារអាមេរិក ៕

**ដោយអរិយបុត្រ**

# ចាស់ខ្លះអត្ថិរក្សចាស់ខ្លះទទួលស្គាល់ជុំវិញការវិវឌ្ឍនៃការស្លៀកពាក់របស់យុវជននិងយុវនារី

សម័យនេះ ខោខូវប៊យសំយេះធ្លាក់គូទសម្រាប់យុវជន និងខោខើចខ្លីរឹបគូទសម្រាប់យុវនារី គឺជាសំលៀកបំពាក់ដ៏ពេញនិយម សម្រាប់ក្រុមយុវជន និងយុវនារីដែលស៊ីវិល័យ នាសម័យឆ្នាំ២០១៥នេះ ។

លោកស្រី សៀក ហ៊ុយ អ្នកលក់សំលៀកបំពាក់មួយរូប នៅផ្សារទួលទំពូងបានអះអាងថា យុវជននិងយុវនារីខ្មែរឥឡូវនេះ គឺកំពុងតែពេញនិយមតែម្តង រឿងខោខូវប៊យសំយេះធ្លាក់គូទ និង ខោខើចខ្លី រឹបគូទនេះ ។

លោកស្រីបានបញ្ជាក់ថា "សម្រាប់ក្មេងៗខោអាវឥឡូវនេះស៊ី ( លក់ដាច់ ) តែខោខូវប៊យសំយេះ ធ្លាក់គូទ និងខោខើចខ្លីរឹបគូទនេះ។ ក្មេងមួយណាក៏ដូចមួយណាដែរ គឺសួររកតែខោអាវនេះ"។

លោកស្រីបានបន្តទៀតថា មិនថាតែក្មេងទេ សូម្បីតែចាស់ៗជាអាណាព្យាបាលផ្ទាល់ ពេលមកទិញខោអាវឲ្យកូនប្រុស កូនស្រីពួកគេមួយចំនួនក៏សួររកខោខូវប៊យ សំយេះធ្លាក់គូទនិងខោរឹបខើចខ្លីនេះផងដែរ ក្រៅពីសួររកទិញ ខោអាវឯកសណ្ឋានកូនទៅរៀន ។

លោកស្រីបានបន្តទៀតថា តម្លៃនៃខោខូវប៊យសំយេះធ្លាក់គូត និងខោខើចខ្លីរឹបគូទនេះគឺមានតម្លៃផ្សេងៗគ្នា តាមសាច់ក្រណាត់ តាមប្រភេទតាមម៉ាកយីហោ តាមថ្មី តាមជជុះ ដោយខ្លះ ៥ ដល់២០ដុល្លារ ឬលើនេះក៏មាន បើជាខោអាវគេទិញចេញពីហាងទំនើបៗ ។

លោកស្រីបានបន្តទៀតថា ខោអាវយុវជន និងយុវនារី គឺភាគច្រើនស៊ីតាមសម័យកាល ហើយការនិយមក៏ដូចគ្នាដែរ គឺប្រែប្រួលតាមសម័យកាល តាមការវិវឌ្ឍរបស់សង្គម ជាក់ស្តែងកាលពីសម័យមុន គឺគេចូលចិត្តគេចូលចិត្តខោខូវប៊យរហែក ហើយសម័យនេះវិវឌ្ឍដល់មិនត្រឹមតែរហែកទេ សំយេះ និង ធ្លាក់គូទទៀតបានគេចូលចិត្ត ហើយយុវនារីវិញ ពីមុនសួររកខោខូវប៊យដែរ តែធម្មតា ក្រោយមក ក៏ចូលចិត្តអារាងរហែក ហើយស្លកបន្តិចៗ ហើយក៏វិវឌ្ឍមកជា ខោរឹបគូទខ្លី តែឥឡូវវិវឌ្ឍឈានដល់រឹបហើយខើចខ្លីថែមទៀត ។

លោកស្រីបានបន្តទៀតថា "ក្មេងស្រីៗខ្លះ សួររកអាខោរឹបខើចខ្លីនេះដល់ក្រលៀនក៏មានដែរ"។

យុវនារីមួយរូប ដែលបានប្រាប់ឈ្មោះត្រឹមថា នីន កំពុងតែឈររើសខោអាវ នៅក្នុងផ្សារទួលទំពូងជាមួយនឹងមិត្តភក្តិរបស់នាង ដែលមានចំនួនពី ៣ទៅ ៤នាក់ បានឲ្យដឹងថាខ្លួនក៏ជាយុវនារីមួយរូប ដែលចូលចិត្តស្លៀកខោរឹបគូទខើចខ្លីនេះដែរ ។

កញ្ញាបានអះអាងថា នៅពេលនេះកញ្ញាមានខោបែបនេះចំនួន ៤សម្រាប់ហើយ ហើយកំពុងតែដើរមើលជាមួយនឹងមិត្តភក្តិ ទិញថែមមួយពីរទៀត ។

កញ្ញាបានអះអាងថា "ខោនេះវារាងដូចជាស៊ិចស៊ីមែន ប៉ុន្តែគេស្លៀកតែតចឹងហើយនោះ ដោយសារតែវាស្រួល មិនទាក់ជើងមិនពិបាកស្លៀកហើយមិនសូវក្តៅ ស្រួលអង្គុយស្រួលដើរ ស្រួលធ្វើនេះធ្វើនោះ ហើយវាស្អាតថែមទៀត "។

កញ្ញាបានបន្តទៀតថា "ឥឡូវនេះមិនមែនស្លៀកតែខ្ញុំទេ គឺគេស្លៀកសឹងតែ ទាំងអស់គ្នាម៉ាប្រទេសហើយ ខ្ញុំក៏មិនជាស្លៀកដដែលៗដែរ គឺជួនស្លៀកអាវែង ជួនស្លៀកអាខ្លីទៅដើម្បីកុំឲ្យវាស៊ុាំ" ។

យុវនារីមួយរូបទៀត ដែលជាមិត្តភក្តិនឹងនីន បានឲ្យដឹងថា កញ្ញចង់ស្លៀកដូចជាមិត្តភក្តិដែរ ដោយសារតែស្លៀកទៅវាស្អាត ប៉ុន្តែកញ្ញាមិនស្លៀកទេ ដោយសារតែកញ្ញាមានស្លាកស្នាមច្រើន។

កញ្ញាបានបញ្ជាក់ថា "បើជើងស្រឡូនស្អាតដូចមិត្តភក្តិអី គឺប្រថុយស្លៀកដែរហើយ តែខ្ញុំមានក្បាលដែកគោល( ស្លាកស្នាម )ច្រើនពេក ក៏ចេះតែស្លៀកជិតៗទៅ"។

កញ្ញាបានបញ្ជាក់ទៀតថា "ជួលកាលពេលដើរ ជាមួយមិត្តភក្តិម្តងៗ ពួកគេចំអន់លេងសើចដាក់ខ្ញុំថា ស្លៀកពាក់ដូចជាស្រែក៏មាន"។

លោក រចនា វិចិត្រ ជាយុវជនមួយរូប ដែលជាអ្នកដែលស្លៀកខោខូវប៊យសំយេះ និងធ្លាក់គូទមួយរូបដែរនោះបានឲ្យដឹងថា សម្រាប់ប្អូន ខោអាវអ្វីក៏ស្លៀកដែរ ហើយការស្លៀកខោខូវប៊យសំយេះ និងធ្លាក់គូទនេះមិនជារហូតទេ គឺផ្លាស់ប្តូរតាមពេលវេលា តាមឱកាសដែលភាគច្រើនគឺប្អូនចូលចិត្តស្លៀកតែពេល ដើរលេងជុំមិត្តភក្តិ និងទៅរៀនអង់គ្លេស ញ៉ាំនេះញ៉ាំនោះតែប៉ុណ្ណោះ។

លោកបានបញ្ជាក់ថា "ខ្ញុំមាន ពីរដែរ ទុកគ្រាន់ស្លៀកម្តងម្កាល"។

លោកបានបន្តទៀតថា វាដូចជាមិនចម្លែកអ្វីនោះទេ វាគ្រាន់តែជាម៉ូតនិងស្ទីលតែប៉ុណ្ណោះ ហើយក៏មិនជាខុសគ្នាអីពីខោផ្សេងៗទៀតដែរ។

ជុំវិញការវិវឌ្ឍ នៃការស្លៀកពាក់របស់យុវវ័យ នាពេលបច្ចុប្បន្ននេះ ចាស់ៗ ដែលជាអាណាព្យាបាលជាជីតារបស់បណ្តាយុវ័យនានា ខ្លះក៏យល់ស្របហើយខ្លះក៏មិនយល់ស្របតាមទស្សនៈរាងៗខ្លួន។

លោកពូ ចំ ចំរើន ដែលជាមន្ត្រីរាជការ ចូលនិវត្តន៍មួយរូប បានមានប្រសាសន៍ថា នេះគឺជាការវិវឌ្ឍនៃសង្គមបើពិភពលោកគេដើរដល់នោះហើយ យើងទើបតែនៅត្រឹមនេះមិនកើតទេចូលសង្គមគេមិនចុះទេ ។

លោកបានបញ្ជាក់ថា "ខ្ញុំមិនជាទុទិដ្ឋិនិយមទេ រឿងការស្លៀកពាក់សំខាន់ចរិតលក្ខណៈ ចរិយា សម្បត្តិ និង ចំណេះវិជ្ជាទេ សម័យមុនពួកខ្ញុំស្លៀកខោជើងប៉ាត់អីដល់សម័យនេះឲ្យចៅឲ្យកូនស្លៀកខោហ្នឹងអីទៀត " ។

លោកបានបន្តទៀតថា ការស្លៀកពាក់វាគ្រាន់តែ ជាសំបកខាងក្រៅទេហើយ វាគឺជាសិល្បៈនៃការតុបតែងខ្លួនរបស់យុវវ័យតែប៉ុណ្ណោះ។ ត្រឹមតែស្លៀកនៅផ្ទះស្លៀកដើរលេង មិនជាអ្វីនោះទេ កុំឲ្យតែស្លៀកទៅសាលារៀន ទៅសាកលវិទ្យាល័យអីវាខុស ឬ ស្លៀកទៅបុណ្យទៅទាន ដែលគេមាន វិន័យមានបទបញ្ជា មានទំនៀមទំលាប់គេហាម។

នេះគឺជាទស្សនៈ បែបទូលាយរបស់មនុស្សជំនាន់មុនមួយរូប ប៉ុន្តែសម្រាប់អ្នកដែល មានគំនិតអភិរក្សបន្តិចគឺដូចជាមិនគាំទ្រគំនិតនេះទេ ។

លោក ស៊ុាំ ចំណាប់ ជាប្រជាពលរដ្ឋមួយរូប បានមានប្រសាសន៍ថា យើងជាខ្មែរមានវប្បធម៌មានប្រពៃណីទំនៀមទម្លាប់និងអរិយធម៌មួយផ្ទាល់ខ្លួនដូច្នេះការស្លៀកពាក់គួរមានគំនិតអភិរក្សខ្លះ ។

លោកបានបន្តទៀតថា សម្លៀកបំពាក់នេះ វាគឺពិតជាវិវឌ្ឍ ប៉ុន្តែគួរណាស់តែការវិវឌ្ឍនេះវាមានព្រំដែន។

លោកបានបញ្ជាក់ថា "ឥឡូវនេះមិនដឹងជាស្អីទេ ទាំងប្រុស ទាំងស្រីស្លៀកពាក់ ដូចជាគ្មានរបៀបរបបសោះ។ ខាងប្រុសនោះគឺស្លៀកសំយេះធ្លាក់គូទ សឹងតែមួយពីរចង្កាមហើយខាងស្រីនោះ ខើចសឹងតែដល់ក្រលៀន ខណៈដែលសម័យមុនត្រឹមតែសាច់កំភួនជើង ស្ត្រីខ្មែរគេមិនឲ្យគេឃើញផង ដល់សម័យឥឡូវនេះផ្សាយពាណិជ្ជកម្ម (បញ្ចេញសាច់) ពេញតែផ្លូវ "៕

**ដោយអរិយបុត្រ**

# ព្រះសហគមន៍កាតូលិកកម្ពុជាប្រកាសបើកការស៊ើបអង្កេតមរណសាក្សីនៅកម្ពុជា

*កាលពីថ្ងៃទី១ ឧសភា ឆ្នាំ២០១៥ ព្រះសហគមន៍កាតូលិក នៅកម្ពុជា បានប្រកាសជាផ្លូវការ នូវការស៊ើបអង្កេតមរណសាក្សីនៅកម្ពុជា ក្រោមអធិបតីភាព លោកអភិបាល នៃព្រះសហគមន៍កាតូលិក ទាំងបីភូមិភាគ នៃកម្ពុជា។ តើដំណើរការនេះ នឹងមានការវិវដ្តយ៉ាងដូចម្តេចទៀត ? **អ្នកនាំសារ** បានធ្វើបទសម្ភាសន៍ជាមួយលោក រឿង ផ័ត្រសិរីជាបូជាចារ្យរៀបចំធ្វើសំណុំឯកសារ ការស៊ើបអង្កេតនេះ។*

**អ្នកនាំសារ ៖** តើក្នុងការប្រកាសជាផ្លូវការនេះមានមរណសាក្សីប៉ុន្មាននាក់?

**លោក រឿង ផ័ត្រសិរី ៖** សព្វថ្ងៃនេះ តាមការស្រាវជ្រាវរបស់យើងតែ មិនទាន់ជាផ្លូវការនៅឡើយទេ មាន៣៥នាក់។ មានលោកអភិបាល ខ្មែរ២នាក់ សាសនទូតក្រៅប្រទេស ពីទីក្រុងប៉ារីសចំនួន៥នាក់ មានបូជាចារ្យប្រចាំស្រុកចំនួន៤នាក់ មានបព្វជិតមកពី២គ្រួសារចំនួន៥នាក់ និងបព្វជិតាចំនួន៧នាក់ និងមានគ្រហស្ថចំនួន១២នាក់។

**អ្នកនាំសារ ៖** តើដំណើរការស្រាវជ្រាវអំពីមរណសាក្សីនៅកម្ពុជាដំណើរការដល់ណាហើយ?

**លោក រឿង ផ័ត្រសិរី៖** យើងស្ថិតនៅក្នុងដំណាក់កាល នៃការចងក្រងឯកសារដើម្បីយកទៅកាត់ក្តី ក្នុងតុលាការក្នុងស្រុក។ យើងកំពុងរៀបចំឯកសាររបស់ពួកគាត់ម្នាក់ៗ ដោយមានឯកសារជាប្រវត្តិសាស្ត្រ នៅក្នុងព្រះសហគមន៍របស់យើង ដែលភាគច្រើន គឺលោកឪពុកប៉ុងសូដ៍បានសរសេរទុក ហើយឯកសារខ្លះទៀតដែលអ្នកជំនិតរបស់មរណសាក្សី ដូចជាញាតិសណ្តាន កូនចៅរបស់គាត់ ឬគ្រីស្តបរិស័ទ ដែលធ្លាប់រស់នៅជាមួយពួកគាត់។ អ្វីៗទាំងអស់នោះយើងប្រមូលមក ដើម្បីរៀបរាប់សម្រាប់ម្នាក់ៗថា នៅសម័យវេទុក្ខវេទនានៅក្នុងរបបប្រល័យពូជសាសន៍ គាត់បានផ្តល់សក្ខីភាព អំពីជំនឿរបស់គាត់យ៉ាងណា ហើយអ្វីដែលអាចធ្វើជាគំរូសម្រាប់គ្រីស្តបរិស័ទ យើងសព្វថ្ងៃនេះបាន។

**អ្នកនាំសារ ៖** តើឯកសារទាំងនេះ នឹងត្រូវបញ្ជូនទៅដល់ណាទៀតទើបក្លាយជា មរណសាក្សីជាផ្លូវការណ៍?

**លោក រឿង ផ័ត្រសិរី៖** ជាធម្មតា ដើម្បីឲ្យមានមរណសាក្សីជាផ្លូវការនៅក្នុងប្រទេសនីមួយៗ យើងត្រូវរៀបចំបើកគណកម្មការតុលាការ វិនិច្ឆ័យ នៃដំណើរការស៊ើបអង្កេតមរណសាក្សីនៃកម្ពុជា ដែលមានពីរកម្រិត។ កម្រិតទី១ យើងហៅថា កម្រិតភូមិភាគ និងកម្រិតចុងក្រោយ គឺក្រោយពី រៀបចំសំណុំរឿងរួចអស់ហើយ យើងជូនទៅទីក្រុងរ៉ូម ដើម្បីធ្វើការស្រាវជ្រាវចុងក្រោយ ពីក្រសួងតែងតាំងអ្នកមានសុភមង្គល ឬសន្តបុគ្គល ដែលជាក្រសួងមួយសំខាន់នៅក្នុងសន្តអាសនៈ ដើម្បីធានាថាករណីដែលកើតឡើង យើងអាចប្រកាស និងអង្វរជាផ្លូវការសម្រាប់ប្រទេសយើងបាន។

**អ្នកនាំសារ ៖** លោកមានប្រសាសន៍ថា តុលាការត្រូវមាននៅក្នុងតំបន់ភូមិភាគតើកម្ពុជានឹងមានយន្តការយ៉ាងណា បើសព្វថ្ងៃនេះព្រះសហគមន៍កម្ពុជា មិនទាន់មានគណកម្មការតុលាការវិនិច្ឆ័យ នៃដំណើរការស៊ើបអង្កេតមរណសាក្សី នៅកម្ពុជានៅឡើយផង?

**លោក រឿង ផ័ត្រសិរី៖** ដើម្បីស៊ើបអង្កេតរឿងទាំងអស់នេះ យើងត្រូវបង្កើតឲ្យមានគណកម្មការតុលាការវិនិច្ឆ័យ នៃដំណើរការស៊ើបអង្កេតមរណសាក្សីនៅកម្ពុជា ដោយខ្លួនឯងហើយនៅថ្ងៃទី១ ខែឧសភា ឆ្នាំនេះ យើងបានប្រកាសបង្កើត គណកម្មការនេះជាផ្លូវការ។ អ្នកដែលធ្វើការនៅក្នុងគណកម្មការនេះ គឺមកពីលោកបូជាចារ្យ បងប្រុស ឬបងស្រី ឬគ្រីស្តបរិស័ទមួយចំនួន ដែលទទួលការតែងតាំងផ្លូវការ ពីលោកអភិបាល ដែលមានមរណសាក្សីដែលស្លាប់លើទឹកដីរបស់គាត់។ នៅកម្ពុជាយើងសហការគ្នា ហើយបានប្រគល់សិទ្ធិឲ្យមកខាងភូមិភាគភ្នំពេញ។ ជាមួយគ្នានេះដែរ យើងក៏ត្រូវដាក់ពាក្យស្នើសុំទៅទីក្រុងរ៉ូមដែរ ដើម្បីឲ្យខាងសន្តអាសនៈដឹងថា ការស្រាវជ្រាវរបស់យើង គឺស្របតាមគំនិតរបស់ព្រះសហគមន៍ និង ត្រូវការគណកម្មការមួយចំនួនផងដែរ ដើម្បីសំរេចកិច្ចការនេះ។

**អ្នកនាំសារ៖** តើបច្ចុប្បន្ននេះយើងមានមនុស្ស គ្រប់គ្រាន់ហើយឬនៅសម្រាប់ដំណើរការគណកម្មការតុលាការវិនិច្ឆ័យ នៃដំណើរការស៊ើបអង្កេតមរណសាក្សីនៅកម្ពុជាមួយនេះ?

**លោក រឿង ផ័ត្រសិរី៖** យើងមានជិតគ្រប់ចំនួនហើយ ដែលយើងនឹងបើកគណកម្មការនេះនៅថ្ងៃទី១ ខែឧសភា។ ដោយសារព្រះសហគមន៍កាតូលិកកម្ពុជាយើងខ្វះខាតធនធានមនុស្ស ដូច្នេះហើយយើងរៀបចំនូវអ្វីដែលចាំបាច់ជាមុនសិន។ យើងមានចំនួន៥នាក់ដែលមានលោកអភិបាល អូលីវីយេ ឝ្មីតអឺស្លែរ ជាអធិបតី លោកបូជាចារ្យ ម៉ារីយ៉ូ ហ្គេស្ស៊ីជាប្រធានអ្នកគាំទ្រសេចក្តីយុត្តិធម៌ លោកបូជាចារ្យ យ៉ាំងលូកាតារ៉ូឡាជាសហការី លោក ប៉ូល រឿង ផ័ត្រសិរី ជាអ្នករៀបចំឯកសារសំណុំរឿង និងអ្នកស្រីទៀង សារ៉ែនជាជំនួយកាសហការី។

**អ្នកនាំសារ ៖** តាមយោបល់របស់លោកឪពុក តើព្រះសហគមន៍កម្ពុជានឹងអាចបញ្ជូនសំណុំរឿងទាំងនេះទៅទីក្រុងរ៉ូមបាន នៅពេលណាដែរ?

**លោក រឿង ផ័ត្រសិរី ៖** ពិបាកនិយាយដែរ រឿងនេះវាស៊ីសងទៅលើការរៀបចំរបស់យើង។ ប្រសិនបើយើងមានដំណាក់កាលទៀងទាត់ ឬក៏មាន អ្នកផ្តល់សាក្សីហ្នឹងគ្រប់គ្រាន់ យើងអាចលឿនដែរ។ តែជាទូទៅ យើងអាចនិយាយរួមបានថា មិនតិចជាង១ឆ្នាំទេ ឬ២-៣ឆ្នាំ ឬ៥ឆ្នាំក៏អាចនិយាយបាន។វាទៅតាមអ្វីដែលយើងអាចប្រមូលបានក្នុង ពេលស៊ើបអង្កេតនេះ។

**អ្នកនាំសារ ៖** បន្ទាប់ពីព្រះសហគមន៍កម្ពុជា មានមរណសាក្សីជាផ្លូវការហើយ តើនឹងមានយន្តការអ្វីបន្តទៀត?

**លោក រឿង ផ័ត្រសិរី៖** តាមពិតគោលដៅរបស់យើងគឺពួកគាត់ក្លាយជាសន្តបុគ្គល។ នៅក្នុងជំនឿព្រះសហគមន៍កាតូលិក សន្តបុគ្គលជាមនុស្សគំរូសម្រាប់គ្រីស្តបរិស័ទ និងជាអ្នកសុំអង្វរព្រះជាម្ចាស់ សម្រាប់មនុស្ស និងគ្រីស្តបរិស័ទដែលរស់នៅក្នុងលោកនេះ ដោយសារយើងជឿថាគាត់នៅក្បែរព្រះជាម្ចាស់ជាងយើង។ ដើម្បីអាចទៅដល់សន្តបុគ្គល យើងអាចមានផ្លូវដើរពីរ គឺទីមួយ ជាអ្នកដែលស្លាប់ បាត់បង់ជីវិតដោយសារជំនឿ ដែលយើងហៅថា មរណសាក្សី និងទី២ គឺអ្នកដែលមានគុណធម៌ជាវិរជនខាងជំនឿ ជាគំរូដល់គ្រីស្តបរិស័ទឯទៀត គឺគាត់រស់នៅប្រកបដោយជំនឿ ហើយមិនស្លាប់ដោយសារជំនឿ ឬការបៀតបៀនទេ។ ផ្លូវទាំងពីរនេះគឺជាឋានៈដែលយើងហៅថាអ្នកដែលមានសុភមង្គល។ សម្រាប់កម្ពុជាយើង យើងមានប្រភេទមរណសាក្សី មានន័យថា ក្រោយពីបានគណកម្មការតុលាការវិនិច្ឆ័យ នៃដំណើរការ ស៊ើបអង្កេតមរណសាក្សីនៅកម្ពុជាហើយ ប្រសិនបើខាងសន្តអាសនៈយល់ព្រម យើងអាចឡើងជាអ្នកមានសុភមង្គលបានតែម្តង ។ បន្ទាប់មក គឺអ្នកដែលមានសុភមង្គលត្រូវបង្ហាញការអស្ចារ្យតាមរយៈ ការអង្វរសុំរបស់យើង ហើយតាមរយៈគាត់ ព្រះជាម្ចាស់ក៏ប្រទានលើអ្វីដែលគាត់សុំ។ ឧទាហរណ៍ ការសុំឲ្យជាសះស្បើយពីជំងឺដែលអ្នកវិទ្យាសាស្ត្រមិនអាចបកស្រាយបានជាដើម។

**អ្នកនាំសារ ៖** តើសន្តបុគ្គល និងអ្នកមានសុភមង្គលនេះ ខុសគ្នាយ៉ាងដូចម្តេច?

**លោក រឿង ផ័ត្រសិរី៖** តាមពិតទាំងពីរប្រភេទនេះគឺសន្តហើយ តែសម្រាប់អ្នកមានសុភមង្គល យើងអាចអធិដ្ឋាន នៅក្នុងពិធីបុណ្យបានត្រឹមតែក្នុងប្រទេសរបស់យើង ឬក្នុងក្រុមបព្វជិត - ជិតារបស់យើង តែប៉ុណ្ណោះ។ យើងមិនអាចដាក់ឈ្មោះគាត់ នៅក្នុងប្រតិទិនព្រះសហគមន៍សកល ដែលមានថ្ងៃគោរពគាត់ជាផ្លូវការ សម្រាប់ព្រះសហគមន៍ទាំងមូលបានទេ។កាលណាគាត់ក្លាយជាសន្តបុគ្គល គឺមានន័យព្រះសហគមន៍ទូទាំងពិភពលោក អាចអធិដ្ឋានអង្វរគាត់ នៅក្នុងពិធីបុណ្យបានជាផ្លូវការ និងជាសាធារណៈទូទាំងពិភពលោកតែម្តង។

**អ្នកនាំសារ៖** តើការមានមរណសាក្សីនៅក្នុងប្រទេសកម្ពុជានឹងជួយអ្វីខ្លះ ដល់គ្រីស្តបរិស័ទក្នុងប្រទេសនេះ?

**លោក រឿង ផ័ត្រសិរី៖** ព្រះសហគមន៍ចាត់ទុកពួកគាត់ ទី១គឺជាគំរូខាងជំនឿ ព្រោះពួកគាត់អនុវត្ត

# ពាំនោលកម្មករ " នយោបាយជារឿងនយោបាយ តែកម្មករដូចខ្ញុំត្រូវការគឺប្រាក់ខែខ្ពស់ បរិយាកាសការងារនិងរស់នៅប្រសើរ "



*កម្មករទាមទារប្រាក់ខែគោល១៧៧ដុល្លារ កាលពីឆ្នាំ២០១៤កន្លងទៅ។*

កម្មករនិងកម្មការនីដែលកំពុងតែបំរើការងារ នៅក្នុងវិស័យឧស្សាហកម្មធន់ស្រាលនៅកម្ពុជា បានអះអាងថាពួកគេមិនយល់ពីនយោបាយទេ ប៉ុន្តែពួកគេចង់បានការងារដែលមានប្រាក់ខែខ្ពស់ មានបរិយាកាសការងារល្អ និងកន្លែងរស់នៅដែលសមរម្យលើសពីបច្ចុប្បន្ន ខណៈដែលប្រមុខរដ្ឋាភិបាលកម្ពុជា នៅក្នុងសារលិខិតសម្រាប់ឱកាសទិវាពលកម្មអន្តរជាតិខួបលើកទី ១២៩ បានបង្ហាញអំពីផែនការធ្វើឲ្យកាន់តែប្រសើរដល់ជីវិតកម្មករ និងកម្មការនី និងមន្ត្រីរាជការស៊ីវិល ។

កញ្ញា រិន ចរិយា ជាកម្មករនៅរោងចក្រម៉ុំទួលសង្កែបានអះអាងថាកញ្ញាមិនដែលខ្វល់ ពីរឿងនយោបាយទេ ប៉ុន្តែកញ្ញា ក៏ធ្លាប់ចូលរួមសកម្មភាពនានា ដូចជាបាតុកម្មមួយចំនួនដែរ ដើម្បីតស៊ូ ឲ្យបានស្ថានភាពការងារ និងប្រាក់ខែសមរម្យជីវភាពមានភាពប្រសើរ។

កញ្ញាបានបញ្ជាក់ថា "នយោបាយជារឿងនយោបាយ តែកម្មករដូចខ្ញុំត្រូវការ គឺប្រាក់ខែខ្ពស់ បរិយាកាសការងារ និងរស់នៅប្រសើរប៉ុណ្ណោះ" ។

កញ្ញា ចរិយា ត្រូវបានគេដឹងថា គឺជានារីកម្មករកាត់ដេរនេះប្រមាណជា ៥ ឆ្នាំមកហើយនោះ បានអះអាងថាឥឡូវនេះ និងពីមុន គឺមានភាពខុសគ្នាខ្លះៗដែរប៉ុន្តែអ្វីដែលសំខាន់គឺជីវិតកម្មកររបស់កញ្ញា គឺមានស្ថានភាពអីមិនខុសពីមុននោះទេ។

កញ្ញាបានបញ្ជាក់ថា "ដំបូងខ្ញុំចូលធ្វើការបានប្រាក់ខែ ៨០ ដុល្លារ ឥឡូវនេះ១២៨ ហើយ មានថែមម៉ោងអីខ្លះ គឺឡើងដល់១៥០ ទៅ១៦០ ជួន២០០ដុល្លារក៏មាន តែខ្ញុំនៅតែរិះថាំ ( សន្សំសំចៃ ) ដែរ"។

កញ្ញា បានបន្តទៀតថា អ្វីដែលខុសប្លែករវាងពេលនេះ និងពេលមុន គឺមានប្រាក់ខែច្រើន ពួករដ្ឋបាលនិងសន្តិសុខរោងចក្រអីក៏មិនសូវស្តីឲ្យ ឬមាត់ធំដាក់កម្មករនោះទេ ប៉ុន្តែអ្វីដែលសំខាន់ អាហារពួកយើងហូបយ៉ាងម៉េច កន្លែងពួកយើងធ្លាប់គេងយ៉ាងម៉េច គឺនៅតែតចឹងអត់មានខុសអ្វីកាលពី ៥ ឆ្នាំមុននោះទេ ។

លោក ចក់ សំរិទ្ធ កម្មករជ្រលក់ពណ៌ក្រណាត់ បានអះអាងថាពេលកំពុងទិញអាហារពេលល្ងាច ពេលចេញពីធ្វើការ ជាអាហារសម្រាប់ក្លែមជុំគ្នាពេលល្ងាច មានដូចជា ត្រីឆ្លូញ-អាំង ត្រីងៀត និង បាយ សម្លរចំអិនស្រាប់នៅតាមដងផ្លូវផ្សារតូច បានអះអាងថា ប្រាក់ខែវាច្រើន តែប្រាក់ខែទេ តែរបស់ក៏វាថ្លៃដែរ ដូច្នេះបើចង់ក្លែមសាច់កាប់ ភ្លៅមាន់បំពងអីដូចគេ គឺបានត្រឹមតែយូៗម្តងតែប៉ុណ្ណោះ។

លោកបានបញ្ជាក់ថា "ប្រាក់ខែត្រឹម ១៥០ អី តែហ៊ានសាច់កាប់តែពីរដង (សាច់កាប់មួយគីឡូក្រាម ៥០.០០០រៀល) គឺអស់ប្រាក់ខែម៉ាភាគបាត់ភ្លាម"។

លោកបានបន្តទៀតថា ឥឡូវនេះបានស្រួលបន្តិច ដោយសារបានភ្លើងថោក ម៉ាគីឡូ ៦០០រៀល ប៉ុន្តែប៉ុន្មានថ្ងៃនេះក្តៅខ្លាំង បើកកង្ហារទើសៗភ្លឺឡើងទៅមើលកុងទ័រភ្លើង ឃើញចង់អស់២៥គីឡូ ហើយខណៈពីមុនអស់មួយខែត្រឹមតែ១០ ទៅ១៥ គីឡូតែប៉ុណ្ណោះនោះ។

នេះគឺជាសម្លេងរបស់កម្មករ និងកម្មការនីនៅកម្ពុជាខណៈដែលរបាយការណ៍របស់រដ្ឋាភិបាលកម្ពុជា បានអះអាងថាស្ថានភាពក្នុងវិស័យផលិតកម្មសម្លៀកបំពាក់នៅកម្ពុជា ដែលជាប្រភពការងារដល់កម្មករ និងកម្មការនីកំពុងតែប្រសើរ ។

យោងទៅតាមសារលិខិត របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឱកាសទិវាពលកម្មអន្តរជាតិខួបលើកទី១២៩ ដែលបានផ្សព្វផ្សាយ កាលពីពេលថ្មីៗកន្លងទៅនេះ បានឲ្យដឹងថា កម្ពុជាបានក្លាយទៅជាប្រទេសមួយ ក្នុងចំណោមប្រទេស ៥ ដែលមានកិត្តិនាមល្អបំផុត ក្នុងវិស័យផលិតផលសម្លៀកបំពាក់ ហើយកាលពីឆ្នាំ ២០១៤ កន្លងទៅនេះ ប្រទេសកម្ពុជា ត្រូវបានជាប់ឆ្នោតជាសមាជិកពេញសិទ្ធិ នៃក្រុមប្រឹក្សាភិបាលអង្គការអន្តរជាតិ ខាងការងារ (ILO) សម្រាប់អាណត្តិ ឆ្នាំ២០១៤ ដល់ ២០១៧ ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ។

សារលិខិតនោះ បានបង្ហាញអំពីការខិតខំប្រឹងប្រែង របស់រដ្ឋាភិបាលដើម្បីធានាឱ្យកម្ពុជា នៅតែរក្សាបាននូវសុវត្ថិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់នៅទូទាំងប្រទេស និង រក្សាបាននូវកំណើនសេដ្ឋកិច្ច និង ការដាក់ចេញនូវការកែទម្រង់ស៊ីជម្រៅមួយចំនួន នៅក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ ២០១៤ - ២០១៨ បានជំរុញបង្កើតការងារថ្មីៗ ក្នុងស្រុកជាច្រើនទៀតជូនប្រជាពលរដ្ឋ ក៏ដូចជាគោលនយោបាយ អភិវឌ្ឍវិស័យឧស្សាហកម្មឆ្នាំ ២០១៥ - ២០២៥ ដែលគោលនយោបាយនេះ នឹងចូលរួមចំណែក ដល់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

នៅក្នុងសារលិខិតរបស់ សម្តេចតេជោ ក៏បានបង្ហាញផងដែរ អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះសុខទុក្ខ និងជីវភាពរស់នៅរបស់កម្មករ កម្មការិនី និងនិយោជិតទាំងអស់ ដោយរាជរដ្ឋាភិបាលបានអនុវត្តន៍សិទ្ធិសេរីភាព អង្គការ វិជ្ជាជីវៈរបស់កម្មករ និយោជិត និង និយោជកស្របតាមច្បាប់ និង បទបញ្ញត្តិការងារ ត្រូវបានធានានិងលើកកម្ពស់ ដោយបច្ចុប្បន្នមានសមាគមសហជីព និងអង្គការចុះបញ្ជីការចំនួនជាង ៣.០០០ ក្នុងនោះ សហភាព សហជីព ចំនួន១៤ សហព័ន្ធសហជីព ចំនួន៨៦ និង សមាគមនិយោជកចំនួន៧។ រាជរដ្ឋាភិបាល បន្តពង្រឹងយន្តការទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈគណៈកម្មការប្រឹក្សាកាងារ ក្រុមការងារ ទំនាក់ទំនងវិជ្ជាជីវៈរវាងរាជរដ្ឋាភិបាល ជាមួយវិស័យឯកជន និង ការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ជា-ពិសេស ការប្រើប្រាស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងកំពុងជំរុញការរៀបចំច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីតុលាការការងារ។

នៅកម្ពុជា មានសហគ្រាសសរុបទូទាំងប្រទេស ចំនួនប្រមាណជាង ៥១មុឺនសហគ្រាស ដោយឡែកវិស័យ ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង មានរោងចក្រ ១.០៨៧ និងមានកម្មករនិយោជិតចំនួនប្រមាណ ៧០ មុឺននាក់ ដោយទទួលបានប្រាក់ឈ្នួលជាមធ្យមប្រមាណជា ១.០០០ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ព្រមទាំងបានបង្កើតមុខរបរប្រយោល បន្ថែមដូចជាជួលផ្ទះ លក់ដូរម្ហូបអាហារ ដឹកជញ្ជូនដល់ប្រជាជន ប្រមាណពីរលាននាក់។ តម្លៃសរុបនៃការនាំចេញផលិតផល ផ្នែកកាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើងបានកើនខ្ពស់ជារៀងរាល់ឆ្នាំ ដោយឡែកឆ្នាំ២០១៤ មានចំនួនប្រមាណជាង ៦.០០០លានដុល្លារ ។ ក្រៅពីការងារក្នុងស្រុកក្នុងឆ្នាំ២០១៤ មានពលករជាង៧២មុឺននាក់ ទទួលបានការងារធ្វើនៅក្រៅប្រទេសដែលបាននាំប្រាក់ចំណូលមកក្នុងប្រទេសជាង១.០០០ លានដុល្លារក្នុងមួយឆ្នាំ៕

**ដោយអរិយបុត្រ**

# ពលរដ្ឋកម្ពុជាស្វាគមន៍វប្បធម៌សន្ទ

ពលរដ្ឋកម្ពុជាទំនង ជាស្វាគមន៍ ចំពោះស្មារតី នៃវប្បធម៌សន្ទនា ដែលបង្កើតឡើង ដោយមេដឹកនាំនយោបាយធំៗនៅកម្ពុជា ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ម្នាក់ៗអះអាងអំពីការបារម្ភថា អាយុរបស់វប្បធម៌នេះគឺវាខ្លី ។

កំពុងអង្គុយអានកាសែត នៅក្នុងតូបកាហ្វេមួយកន្លែង នៅមុំផ្សារស្ទឹងមានជ័យរង់ចាំទទួល ភរិយាចេញពីផ្សារលោក ដេត កុម្ភៈ ជាប្រជាពលរដ្ឋមួយរូបបានអះអាងថា តាំងពីលោក សម រង្ស៊ី បង្កើតគណបក្សប្រឆាំង ក្រោយចាកចេញពី ហ៊្វុនស៊ីនប៉ិច មក គឺលោកទើបតែប្រទះឃើញ លោកស្និតស្នាល ជាមួយនឹងគណបក្សកាន់អំណាច ជាពិសេសជាមួយនឹងសម្តេចតេជោ ហ៊ុន សែន ជាលើកទីមួយបែបនេះ។

លោកបានបន្តបញ្ជាក់ថា "ប្លែកណាស់ ដែលមេបក្សប្រឆាំងស៊ីខ្សែជាមួយនឹងសម្តេច ហ៊ុន សែន "។

លោក បានបន្តទៀតថា តាម ប្រវត្តិនយោបាយលោក សម រង្ស៊ី ភាគច្រើន គឺប្រកាន់ជំហររឹងតឹងណាស់ នៅក្នុងការធ្វើការជាមួយគណបក្សកាន់អំណាច ប៉ុន្តែជំហរដែលយើងទាំងអស់គ្នា បានឃើញកាលពីចូលឆ្នាំ និងថ្មីៗនៅក្នុងប្រទេសម៉ាឡេស៊ី គឺបង្ហាញពីភាពចុះសំរុងខាងនយោបាយមួយ ដូចជានៅស្រុកគេដែរ ។

លោកបានបន្តទៀតថា បើស្ថានភាពនយោបាយ នៅកម្ពុជាបែបនេះរហូត ប្រហែលជារាស្ត្រសប្បាយចិត្តណាស់ ពីព្រោះវាបង្ហាញថា សង្គមកម្ពុជា មានប្រជាធិបតេយ្យពិតប្រាកដមួយដូចគំរូនៅអាមេរិកដែរ។

លោកបានបញ្ជាក់ថា មើលអាមេរិក ពេលបោះឆ្នោត លោក ប៉ារ៉ាក អូបាម៉ា និង លោក ចន ឃែរី ព្រលះគ្នាមិនអន់ទេ ដើម្បីតំណែងប្រធានាធិបតី ប៉ុន្តែក្រោយពេលបោះឆ្នោតចប់ ម្នាក់ធ្វើប្រធានាធិបតី ម្នាក់ធ្វើរដ្ឋមន្ត្រីការបរទេស ចែកគ្នាធ្វើការ ដូច្នេះបើកម្ពុជា មានស្ថានភាពបែបនេះដែរ នោះ គឺពិតជាល្អមែនទែន។

លោក ជុំ កំរ៉ង ជាមន្ត្រីរាជការមួយរូបបានមានប្រសាសន៍ថា ស្រុកយើងនឹងមានស្ថេរភាពនយោបាយ បើគណបក្សកាន់អំណាច និងគណបក្សបក្សប្រឆាំងចេះរួបរួមគ្នាធ្វើការ ដើម្បីប្រយោជន៍ជាតិ ដូចដែលបានឃើញតាមកញ្ចក់ទូរទស្សន៍ និងបណ្តាញព័ត៌មាន កាលពីពេលថ្មីៗនេះ ប៉ុន្តែអ្វីដែលលោកបារម្ភ គឺជាការសម្តែងតែមួយរយៈពេលខ្លី ។

លោកបានបញ្ជាក់ថា "បើបក្សកាន់អំណាច និងបក្សប្រឆាំងធ្វើបានតែរបៀបនេះ ស្រុកយើងសាន្តត្រាននឹងគេហើយ ប៉ុន្តែខ្ញុំចេះតែភ័យថា អាយុកាលនៃស្ថានភាពបែបនេះ វាមានមិនយូរ"។

លោកបានបន្តទៀតថា សង្គមប្រជាធិបតេយ្យ គេរិះគន់គ្នា ជេរគ្នា តែនៅក្នុងពេលបោះឆ្នោតទេ ដល់ពេលបោះឆ្នោតហើយ គឺគេរួមគ្នាធ្វើការតាមតួនាទីហើយ។ លោកបានបន្តថា បើនរណាជាប់ឆ្នោតគេមកដឹកនាំ រដ្ឋាភិបាល ហើយអនុវត្តតាមគោលនយោបាយដែលគេឃោសនាទៅ ហើយគណបក្សដែលចាញ់ គឺជាគណបក្សប្រឆាំង ដែលចាំមើលការអនុវត្តនយោបាយនោះហើយរិះគន់ស្ថាបនា ស្វែងរកអ្វីដែលជាចំណុចអសកម្ម នៃការអនុវត្តកម្មវិធីនយោបាយ របស់គណបក្សកាន់អំណាច ដើម្បីឲ្យប្រជាពលរដ្ឋបានជ្រាប បានដឹង និងជាពិសេស គឺជាប្រយោជន៍សម្រាប់សង្គមទាំងមូលតែម្តង។

លោក ដេត កុម្ភៈ បានមានប្រសាសន៍សង្កត់ធ្ងន់ថា ប្រសិនបើសង្គមកម្ពុជា អនុវត្តតាមវប្បធម៌សន្ទនាបែបនេះជារាងរហូត នោះប្រហែលជាសង្គមកម្ពុជា នឹងរីកចំរើនទៅមុខជានិច្ចពីព្រោះនៅពេលមានបញ្ហាអី គឺគេត្រូវអង្គុយជជែកគ្នា យកផលប្រយោជន៍សាធារណៈជាធំ។

វប្បធម៌សន្ទនានេះ ត្រូវបានអះអាង គឺជាសមិទ្ធិផលដែលបង្កើតឡើងដោយសម្តេចតេជោ ហ៊ុន សែន ដែលបច្ចុប្បន្ន ជានាយករដ្ឋមន្ត្រី និងជាអនុប្រធានគណបក្ស ប្រជាជនកម្ពុជា និងលោក សម រង្ស៊ី ដែលជាប្រធានក្រុមសភាភាគតិច នៅក្នុងសភានិងជាប្រធានគណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំង។

លោក ដេត កុម្ភៈ បានបន្តទៀតថា នៅក្នុងសង្គមមួយ វាដូចជានៅក្នុងគ្រួសារដូច្នេះដែរ បើឃើញនៅក្នុងគ្រួសារបើកភ្នែកឡើងឃើញតែម៉ែនិងឪចេះតែជេរប្រទេចគ្នា ហិង្សាដាក់គ្នា



## វប្បធម៌សន្ទនារកកល់រង្គោះរង្គើ

សម្តេចតេជោហ៊ុនសែនកាលពីថ្ងៃទី២៩ខែមេសា នាខេត្តព្រះសីហនុ បានដាក់សំណួរទៅ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ អំពីវប្បធម៌សន្ទនាថាតើចង់បន្តឬបញ្ឈប់។ថ្លែងនៅក្នុងពិធីសម្ពោធរោងចក្រម៉ុងឬទ្ធី សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា បើចូលទាត់ត្រូវទាត់ទាំងអស់គ្នា មិនមែនគ្នា ១១នាក់ ទុកពីរឲ្យចាំទាត់ជើងនោះទេ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា សម្រាប់វប្បធម៌សន្ទនានេះ ខាងគណបក្សប្រជាជន គឺបានចេញគោលការណ៍ណែនាំសមាជិករួចរាល់ហើយ តាំងពីលើដល់ក្រោម នៅពេលនេះកំពុងតែរង់ចាំខាងគណបក្សសង្គ្រោះជាតិ ចេញការណែនាំផ្លូវការដល់សមាជិករបស់ខ្លួនប៉ុណ្ណោះ។សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថាគណបក្សប្រជាជនកម្ពុជា គឺមានជំហរនយោបាយច្បាស់លាស់ណាស់។

ឆ្លៀតឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ដែលជាអនុប្រធានគណបក្សប្រជាជនកម្ពុជា បានថ្លែងសារនយោបាយបង្ហើបពីបេក្ខភាព ប្រធានគណបក្ស និង ប្រធានព្រឹទ្ធសភា ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា សម្តេច ជា ស៊ីម នៅតែជាប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានព្រឹទ្ធសភា ប៉ុន្តែនៅពេលអវត្តមានសម្តេច សម្តេចតេជោខ្លួនឯង នឹងក្លាយជាប្រធានគណបក្ស ហើយលោក សាយ ឈុំ ដែលជាអគ្គលេខាធិកាគណបក្ស និងជាអនុប្រធានព្រឹទ្ធិសភានឹងក្លាយជាប្រធានព្រឹទ្ធសភា។នៅក្នុងឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានប្រកាសអំពីភាពរឹងមាំផ្ទៃកនយោបាយរបស់គណបក្សប្រជាជន ហើយអះអាងថា សម្តេចនឹងបន្តជាបេក្ខភាពនាយករដ្ឋមន្ត្រីរបស់គណបក្សប្រជាជនកម្ពុជា នៅអណត្តិទី៦ និងអណត្តិបន្តទៀត៕

# ...នាតែខ្លាចវប្បធម៌នេះមានអាយុខ្លី



តើគ្រួសារមានសុភមង្គលពីណា សេដ្ឋកិច្ចគ្រួសារយ៉ាងម៉េច បើរស់តែកើតទុក្ខ រស់តែព្យាបាលរបួសនោះ ផ្ទុយទៅវិញ បើគ្រួសារមានភ័ព្វសំណាងមានឪពុកម្ដាយ ចេះយោគយល់គ្នា ចេះជួយគ្នា គ្រួសារក៏វាមានសុភមង្គលទៅតាមនោះដែរ ដោយឡែកប្រទេសក៏ដូច្នេះដែរ បើមេដឹកនាំឈ្លោះតែគ្នា តើឲ្យប្រជាពលរដ្ឋសង្ឃឹមលើអី បើតំណាងរបស់ខ្លួន ដែលខ្លួនទុកចិត្តចេះបានត្រឹមតែ រករឿងមកឲ្យខ្លួនចំបែងចិត្ត និងភ័យព្រួយតែរហូតមកនោះ។

នេះគឺជាការយល់ឃើញ របស់ប្រជាពលរដ្ឋសាមញ្ញ អំពីបច្ចុប្បន្នភាពនៃស្ថានភាពនយោបាយនៅ កម្ពុជាជុំវិញបញ្ហាវប្បធម៌សន្ទនានេះ ប៉ុន្តែសម្រាប់មជ្ឈដ្ឋានបញ្ញវន្តវិញ ក៏មានការយល់ឃើញ ប្រហាក់ប្រហែលគ្នានេះផងដែរ។

លោក សំបូរ មាណ្ណ៉ារ៉ា សាស្ត្រាចារ្យប្រវត្តិសាស្ត្រ បានមានប្រសាសន៍ថា វាគឺជាការប្រសើរណាស់ ដែលខ្មែរយើងយកវប្បធម៌សន្ទនាគ្នានេះ យកមកប្រើប្រាស់ឡើងវិញនៅក្នុងសង្គម ។

លោកបានបន្តទៀតថា វប្បធម៌សន្ទនាគ្នានេះ គឺមាននៅក្នុងប្រវត្តិសាស្ត្រ ហើយនៅគ្រប់ជំនាន់ដែលខ្មែរអនុវត្តនយោបាយនេះ សង្គមកម្ពុជា គឺតែងតែមានភាពរុងរឿងជាក់ស្ដែងដូចសម័យអង្គរ សម័យចតុមុខ សម័យសង្គមរាស្ត្រនិយម ។ល។

លោកបានបញ្ជាក់ថា "បើខ្មែរបន្តរក្សាវប្បធម៌សន្ទនាគ្នានេះ បន្តទៀត ខ្ញុំជឿថា អ្នកប្រវត្តិសាស្ត្រ និងកត់ត្រា ៥ចំណុច គឺទី១ ខ្មែរសម័យនេះមាននយោបាយជាតិស្រឡះល្អ ទី២ខ្មែរអាចដោះស្រាយបញ្ហាជាតិ បានដោយការស្រុះស្រួលនិយាយគ្នា ទី៣សហគមន៍ខ្មែរមានការរួបរួមគ្នា ទី៤ គឺខ្មែរទទួលការទុកចិត្តពីបរទេស ហើយចុងក្រោយ គឺខ្មែរនឹងបង្កើនទំនាក់ទំនងសហគមន៍អន្តរជាតិរីកចម្រើន" ។

ជុំវិញបញ្ហាវប្បធម៌ សន្ទនានេះ លោក ព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ថាភាពស្ងប់ស្ងាត់នៃនយោបាយកម្ពុជា គឺវាមានអាយុកាលទៅតាមភាពចាស់ទុំនៃអ្នកនយោបាយនៅកម្ពុជា ។

លោកបានបញ្ជាក់ថា "កត្តានេះ គឺវាអាស្រ័យថា តើអ្នកនយោបាយនៅកម្ពុជាយើង មានភាពចាស់ទុំខាងនយោបាយនេះប៉ុណ្ណា ពីព្រោះនៅក្នុងនយោបាយ គឺប្រហែលជាមិនមានការស្របគ្នារហូតទេ គឺត្រូវតែមានការខ្វែងគំនិតគ្នាមានការរិះគន់គ្នា"។

លោកបានបន្តទៀតថា ពាក្យថា វប្បធម៌សន្ទនានេះ មិនមែនមានន័យថា ជាការជួបគ្នានិយាយស្របជាមួយគ្នាផ្អែមល្ហែមជាក់គ្នាទាំងអស់នោះទេ។ ត្រង់ន័យនេះ គឺមានន័យថា អ្នកនយោបាយ គឺត្រូវតែនិយាយគ្នា ទោះបីជាមិនឯកភាពគ្នា ខ្វែងគំនិតគ្នា រិះគន់គ្នាក៏ដោយ តែនៅតែនិយាយរកគ្នា។

លោកបានបញ្ជាក់ថា "សង្គមប្រជាធិបតេយ្យ គឺអត់មាននយោបាយណាដែលឲ្យនិយាយស្របគ្នា ទាំងអស់នោះទេ និយាយល្អកល្អើនគ្នា ហើយឯកភាពគ្នា ជាឯកច្ឆន្ទនោះ គឺអត់មានទេ"។

លោកបានបន្តទៀតថា ដូច្នេះអ្នកនយោបាយ និងប្រជាពលរដ្ឋទាំងអស់ ត្រូវយល់អំពីវប្បធម៌សន្ទនានេះឲ្យច្បាស់ ប្រយ័ត្នមានការខកចិត្ត ។

លោកបានចូលរួម ផ្ដល់យោបល់បន្ថែមទៀតថា ដើម្បីឲ្យសង្គមកម្ពុជាកាន់តែមានភាពរឹងមាំផ្នែកនយោបាយ និងភាពស្រុះស្រួលគ្នាបន្ថែមទៀត គឺអ្នកនយោបាយ គួរគិតវប្បធម៌មួយទៀត គឺវប្បធម៌យោគយល់គ្នា និងអធ្យាស្រ័យគ្នា ។

លោកបានបន្តទៀតថា តាមរដ្ឋធម្មនុញ្ញ ដែលកំណត់សាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ វប្បធម៌យោគយល់គ្នា និងអធ្យាស្រ័យគ្នានេះក៏សំខាន់ណាស់ដែរ។

លោកបានបន្តទៀតថា វាគឺជាការត្រឹមត្រូវដែលអ្នកនយោបាយ នៅកម្ពុជាបានចាប់យកនូវ ការសន្ទនាគ្នា ហើយដោះស្រាយបញ្ហាតាមរយៈការជជែកគ្នានេះ វាមានប្រយោជន៍នៅត្រង់ថា វាធានាបាននូវសន្តិភាពស្ថេរភាពនយោបាយ និងវាមិនមានហិង្សា វាជាការធ្វើឲ្យ អ្នកគាំទ្រនៅមូលដ្ឋានមានការសន្ទនាគ្នា ពោលគឺធ្វើឲ្យខ្មែរមានឯកភាពគ្នា ទោះបីជាមាននិន្នាការនយោបាយផ្សេងគ្នាក៏ដោយ ។

លោក សុខ សំអឿន នាយកប្រតិបត្តិ នៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានមានប្រសាសន៍ថា សភាពស្ងប់ស្ងាត់ នៃនយោបាយកម្ពុជា គឺជាទូទៅ គឺមានអាយុកាលប្រហែលជាមួយអណត្តិបោះឆ្នោត ។

លោកបាននិយាយថា នៅពេលបច្ចុប្បន្ននេះ វាពិបាកនៅក្នុងការព្យាករណ៍ទៅរកការបោះឆ្នោត ខាងមុខថា វាមានបញ្ហារំជើបរំជួលខ្លាំង ឬក៏វាអត់មានបញ្ហាអី ដោយសារនៅក្នុងការបោះឆ្នោតលើកក្រោយនេះ គណបក្សនយោបាយគឺសុទ្ធតែខ្លាំង ហើយម្យ៉ាងទៀត នៅក្នុងកងកម្លាំងវិញ គឺយើងអត់ទាន់ឃើញថា ពួកគេមានឯករាជ្យអព្យាក្រឹត្យសុទ្ធសាធ នៅឡើយ ។

លោកបានបញ្ជាក់ថា "សម្រាប់ខ្ញុំពិបាក នៅក្នុងការទស្សន៍ទាយណាស់ ប៉ុន្តែខ្ញុំដឹងថា នៅពេលបោះឆ្នោតលើកក្រោយនេះ គឺនឹងមានការប្រកួតប្រជែងគ្នាខ្លាំង ប៉ុន្តែបើយើងមានវប្បធម៌សន្ទនានេះ ខ្ញុំគិតថាមិនជាអីទ"។

លោកបានបញ្ជាក់ថា "កុំឲ្យតែមានការផ្លោងជាក់គ្នាទៅវិញទៅមក។ ខ្មែរយើងឲ្យតែមេដឹកនាំធំៗជួបគ្នា គឺលែងអីហើយ ប៉ុន្តែណាស់តែមិនព្រមជួបគ្នា"។

លោកបានបន្តទៀតថា កន្លងមកសភាពការតានតឹង គឺកើតមានតែពេលដែលមិនព្រមជួបគ្នា ហើយផ្លោងជាក់គ្នា តាមតែអ្នកនាំពាក្យ និងតាមប្រព័ន្ធផ្សព្វផ្សាយ ។

លោក សុខ សំអឿន មិនបានព្យាករណ៍អំពីអាយុកាល នៃវប្បធម៌សន្ទនាទេ ប៉ុន្តែបានសំដែងនូវភាពជឿជាក់ថា កម្ពុជាអាចនឹងមានស្ថេរភាពនយោបាយនេះបន្តទៀត រហូតដល់ជិតបោះឆ្នោតអណត្តិក្រោយ ៕

**ដោយអរិយបុត្រ**

## លោក សម រង្ស៊ី ប្រកាសផ្ដល់តម្លៃជាថ្មីដល់វប្បធម៌សន្ទនា

លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ក្រោយពេលបង្ហាញវត្តមានជាមួយប្រមុខរដ្ឋាភិបាលកម្ពុជា នៅកូឡាឡាំពួរ កាលពីថ្ងៃទី ២៥ ខែ មេសាថា ការបង្ហាញមុខជាសាធារណៈនេះគឺជាការផ្ដល់តម្លៃជាថ្មីទៀតដល់វប្បធម៌សន្ទនា។

លោកបានមានប្រសាសន៍បញ្ជាក់ថា "វប្បធម៌សន្ទនា គឺជានិមិត្តរូបនៃឯកភាពជាតិខ្មែរនាពេលនេះ"។

លោកបានបន្តទៀតថា វត្តមានរួមគ្នានៅកូឡាឡាំពួរ ពេលសម្ដេចតេជោ ហ៊ុន សែនចូលរួមកិច្ចប្រជុំកំពូលអាស៊ាន ហើយលោកចូលប្រជុំក្រុមប្រឹក្សាអ្នកប្រជាធិបតេយ្យ និងសេរីនិយមអាស៊ាន គឺវប្បធម៌សន្ទនានេះមិនមែនជាវប្បធម៌និយាយបានតែមេដឹកនាំនោះទេ គឺត្រូវពង្រីកដល់កំរិតមូលដ្ឋាន ។

លោកបានបញ្ជាក់ថា នេះគឺជាសារនយោបាយប្រាប់ថា ថ្នាក់ដឹកនាំគណបក្សកាន់អំណាច និងគណបក្សក្រៅរដ្ឋាភិបាល គឺមានការគោរពគ្នាទៅវិញទៅមក ហើយជារបត់នយោបាយថ្មីមួយនៅកម្ពុជា ដែលនឹងនាំមកនៅផ្លែផ្កានិងភាពវិជ្ជមានច្រើន ៕



## ថ្ងៃព្រហស្បត្តិ៍ល





## ថ្ងៃសុក្រដើរបផ្លូវឈើឆ្កាង និ



## ថ្ងៃអាទិត្យបុណ្យចម្លង





## ាងជើង





## ងថ្ងៃសៅរ៍អធិដ្ឋាន









# កែវ ភោគ៖ "ខ្ញុំបម្រើព្រះសហគមន៍ ដើម្បីជួយបងប្អូនក្រីក្រ"


លោក កែវ ភោគ

អង្គុយមុខកុំព្យូទ័រផង ដៃនិយាយទូរស័ព្ទផង និងរត់ចុះរត់ឡើងទាំងស្វាគមន៍ភ្ញៀវ ក្នុងកន្លែងការិយាល័យផង បុរសវ័យ៣៣ឆ្នាំម្នាក់ បានចំណាយពេលជិត១០ឆ្នាំ ដើម្បធ្វើការងារក្នុងព្រះសហគមន៍ ដោយអំណត់ និងដោយសេចក្ដីស្រឡាញ់។

បុរសនេះឈ្មោះ កែវ ភោគ ជាបុគ្គលិក ព្រះសហគមន៍ មណ្ឌលសកម្មភាពកំពត ក្នុងមុខងារជាជំនួយការបូជាចារ្យ និងជាអ្នកគ្រប់គ្រងធនធានមនុស្ស។ លោកភោគបានក្លាយជាបុគ្គលិកព្រះសហគមន៍កំពត ក្នុងឆ្នាំ២០០៥ ហើយគេអាចទុកគាត់ជាមនុស្សបង្គោលសម្រាប់ ព្រះសហគមន៍នៅតំបន់នោះ ដោយជួយចាត់ចែងព្រះសហគមន៍ អប់រំជំនឿជាដើម។ កែវ ភោគ "ដំបូងខ្ញុំជួយគ្រប់គ្រងមណ្ឌលសិស្ស ជាគ្រូអប់រំជំនឿ ជាគណនេយ្យករ និងជាជំនួយការបូជាចារ្យនៅតំបន់កំពត ទាំងមូលដោយសារ នៅក្នុងឆ្នាំ ២០០៥-២០០៦ ពេលហ្នឹងអត់ទាន់មានបូជាចារ្យគ្រប់គ្រាន់។ ហើយបន្ទាប់មក ខ្ញុំត្រូវបានចាត់ ឲ្យទៅអប់រំជំនឿនៅតំបន់មួយចំនួន។ មុនដំបូងជុំគិរីហើយព្រៃប្រស់បន្ទាប់មកទៀតកោះស្លា" ។

បើនិយាយពីថ្ងៃធ្វើការងារ លោកហាក់ដូចគ្មានពេល សម្រាប់ខ្លួនឯងសោះ។ កែវ ភោគ "ថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ខ្ញុំធ្វើការងារនៅក្នុងព្រះសហគមន៍ ហើយថ្ងៃអាទិត្យជាថ្ងៃសម្រាករបស់ខ្ញុំ ខ្ញុំស្ម័គ្រចិត្តធ្វើជាគ្រូអប់រំជំនឿ។ ឥឡូវនេះ ខ្ញុំអប់រំជំនឿនៅព្រះសហគមន៍កោះស្លាជាព្រះសហគមន៍ទើបតែកកើតក្នុងឆ្នាំ ២០១១។ ខ្ញុំចាប់ផ្ដើមជាមួយពួកគាត់ តាំងពីដើមរហូតមកឥឡូវនេះ"។

កម្មវិធីអប់រំជំនឿនេះ លោកត្រូវជិះម៉ូតូរយៈពេល១ម៉ោងកន្លះ ពីក្រុងកំពត ដើម្បីទៅដល់ភូមិកោះស្លា ដោយឆ្លងស្ពាន ឆ្លងកាត់ផ្លូវលំបាកនិងគ្រោះថ្នាក់មួយចំនួនដែរ។ និយាយបណ្ដើរ បើកម៉ូតូ បណ្ដើរ កែវ ភោគ ដំណាលថា ជួនកាល លោកត្រូវក្មេងស្ទាវស្ទាក់វាយម្ដងម្កាលដែរ ហើយពេលខ្លះទៀត លោកក៏ត្រូវជិះធ្លាក់ផ្លូវ ចូលទៅក្នុងព្រៃទៀតផង ដោយសារយប់មានឡានបរកាត់ផ្លូវ ធ្វើឲ្យជីហុយមើលផ្លូវមិនឃើញ។ កែវ ភោគ "ពេលហ្នឹងខ្ញុំចង់តែយំ ហើយគិតថា ហេតុអីបានជាខ្លួន មកធ្វើការបែបហ្នឹង? ម៉ោពិបាកខ្លួន។ ហើយពេលខ្លះ ខ្ញុំថាខ្ញុំឈប់ធ្វើទៀតហើយ"។ យ៉ាងណាមិញ ការងារនេះ លោកបានធ្វើជិត ១០ឆ្នាំមកហើយដែរ ជាមួយបងប្អូននៅតាមព្រះសហគមន៍នានា ដែលជាកន្លែងដែលទើបកកើតដំបូង ដូចជាភូមិកោះស្លានេះ។ ទោះបីជា ការងារស្ម័គ្រចិត្តមួយនេះ ត្រូវចំណាយកម្លាំងប្រាជ្ញាជាច្រើន និង ស៊ីពេលពេញមួយថ្ងៃសម្រាករបស់លោក ក៏ដោយ ក៏ការតាំងចិត្តជាអ្នកបម្រើ ដើម្បីប្រកាសដំណឹងល្អដល់ បងប្អូននៅតំបន់ដាច់ស្រយាលនៅតែមាន។

នៅព្រះសហគមន៍កោះស្លា ពេលលោកទៅដល់ គឺអប់រំជំនឿ បង្ហាត់ចម្រៀង និងបង្រៀនគ្រីស្តបរិស័ទ ទាំងចាស់ក្មេងឲ្យចេះ រៀបចំពិធីបុណ្យ ចេះបម្រើអាសនៈ ចេះអធិដ្ឋាន និងរិះគិតអំពីព្រះបន្ទូល របស់ព្រះជាម្ចាស់។ កែវ ភោគ "ខ្ញុំពន្យល់ពួកគាត់អំពីរបៀបនៃការគោរព និងប្រតិបត្តិនៅក្នុងសាសនាកាតូលិក ទោះបីជាអ្នកខ្លះ គាត់ទទួលជ្រមុជទឹកបាន៣-៤ឆ្នាំហើយក៏ដោយ ក៏គាត់ត្រូវការគ្រូអប់រំជំនឿទៅជួយពង្រឹងគាត់ដែរ"។

កែវ ភោគ បានឲ្យដឹងថា អ្វីដែលជំរុញឲ្យគាត់ធ្វើការងារជិត ១០ឆ្នាំមកនេះ "ដោយសារតែខ្ញុំមើលឃើញព្រះសហគមន៍ចេះជួយអ្នកក្រីក្រ និងអ្នកអស់សង្ឃឹម និងដោយសារព្រះសហគមន៍ជួយខ្ញុំ និងគ្រួសាររបស់ខ្ញុំពេលក្រីក្រ ដែលនាំឲ្យខ្ញុំចង់ជួយអ្នកដទៃ តាមអ្វីដែលខ្ញុំអាចជួយបាន ទោះលំបាក ក្នុងការបម្រើក៏ដោយ"។ លោកភោគបន្តថា ការបម្រើនេះ ក៏អាចមកពីទម្លាប់ដែល លោកបានធ្វើនៅពេលលោកសិស្សនិស្សិត រស់នៅក្នុងព្រះសហគមន៍។ លោក ភោគ "ពេលខ្ញុំជាសិស្ស លោកបូជាចារ្យឲ្យយើង ចេះបម្រើព្រះសហគមន៍ខ្លះៗ ហើយ យើងឃើញសកម្មភាពរបស់លោកបូជាចារ្យ បងស្រី បម្រើបងប្អូនដទៃទៀត ទាំងក្នុងព្រះសហគមន៍ និងសង្គមខ្មែរយើង។ គឺគាត់បើកចិត្តទូលំទូលាយដើម្បីបម្រើ នេះជាគំរូមួយសម្រាប់យើង និងជាសក្ខីភាពមួយដែលធ្វើឲ្យខ្ញុំ ចង់បម្រើព្រះសហគមន៍រួមដំណើរជាមួយពួកគាត់"។

លោក កែវ ភោគ មកពីគ្រួសារពុទ្ធបរិស័ទ។ លោកបានទទួល អគ្គសញ្ញាជ្រមុជទឹក ក្នុងឆ្នាំ២០០៣ នៅភូមិចំការទៀង ខេត្តតាកែវ។

ដោយការងាររវល់ពេក លោករកពេលដើម្បីជួបជុំ ជាមួយភរិយាស្ទើរតែគ្មានឡើយ។ និយាយអំពីរឿងនេះ លោកទម្លាក់ទឹកមុខបន្តិច ហើយបន្តថា "ពិបាកដែរជាមួយប្រពន្ធដោយសារពេលខ្លះគេថាយើងដែរ ការងារអីក៏ការងារគ្មានសៅរ៍គ្មានអាទិត្យ។មិនមែនថាអត់សោះទេ វាមានដែរ តែតិចតួចបំផុត។ ពេលខ្លះទៀតគេ(ប្រពន្ធ) ចង់ទៅណាថ្ងៃបុណ្យអីថ្ងៃឈប់សម្រាកអី ខ្ញុំនៅព្រះវិហារព្រោះអីព្រះវិហារក៏មានកម្មវិធីដូចគ្នាដែរ ដូចជាចូលឆ្នាំភ្ជុំ។ បើយើងអត់ទៅវាមិនកើត។ តែខ្ញុំអរគុណគាត់ដែរ គាត់ទុកពេលនិងទ្រាំជាមួយខ្ញុំរហូតម៉ោ"។

នៅក្នុងពេល បន្តិចទៀតនេះ លោក កែវ ភោគនឹងផ្លាស់ប្ដូរការងារទៅខេត្តតាកែវវិញ ដោយកាន់គម្រោងការងារថ្មីមួយ របស់ព្រះសហគមន៍កាតូលិក ធ្វើការជាមួយមនុស្សចាស់ជរាដែលគ្មានទីពឹង ជាកម្មវិធីរបស់លោកអភិបាលអូលីវីយេ ឝ្មិតអីស្ល៊ែរ។

កែវ ភោគ "ខ្ញុំមិនទាន់ដឹងទេថាការងារថ្មីហ្នឹង យ៉ាងម៉េចនៅឡើយទេ។ ការងារថ្មីនេះខ្ញុំគិតថាវាលំបាកបន្តិច ព្រោះយើងអត់មានបទពិសោធន៍ ប៉ុន្តែ ខ្ញុំនឹងសាកល្បង និងខំប្រឹងឲ្យអស់ពីសមត្ថភាព"។ **ដោយកញ្ញា**

## សន្តីលូស៊ី(ពន្លឺ)



នាងលូស៊ី(ពន្លឺ) រស់នៅប្រទេសអ៊ីតាលីនៅឆ្នាំ៣០០។ នាងថ្វាយខ្លួនទាំងស្រុង ចំពោះព្រះជាម្ចាស់តាំងពីនាងនៅក្មេង។ ថ្ងៃមួយមានបុរសម្នាក់មកដណ្ដឹងនាងធ្វើជាភរិយា តែនាងបដិសេធ។ បុរសនោះខឹងខ្លាំងណាស់ ហើយប្ដឹង ទៅអាជ្ញាធរ ថានាងជាគ្រីស្តបរិស័ទដ៏ឆ្នើមម្នាក់។

សម័យនោះគេ បៀតបៀនគ្រីស្តបរិស័ទ ដូច្នេះគេក៏បញ្ជូននាង លូស៊ី (ពន្លឺ)ទៅតុលាការដើម្បីកាត់ទោស ។ លោកទេសាភិបាល មិនអាចបង្ខំឲ្យនាង បោះបង់ជំនឿចោលបានទេ។ លោកទេសាភិបាលសួរនាងថា៖"តើព្រះវិញ្ញាណដ៏វិសុទ្ធនោះ គង់នៅជាមួយនាងមែនទេ?"។ នាង លូស៊ី ឆ្លើយថា៖ "អ្នកមានចិត្តបរិសុទ្ធ អ្នកនោះជាព្រះដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធហើយ"។លោកទេសាភិបាលឆ្លើយខ្លាំងៗថា៖ "ដូច្នេះយើងត្រូវធ្វើឲ្យនាងប្រព្រឹត្តអំពើបាប ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធនោះចាកចេញពីនាងមែនទេ?"។ នាងឆ្លើយទៅវិញថា៖ "នាងខ្ញុំនឹងមិនប្រព្រឹត្តអំពើទុច្ចរិតណាមួយទេ ដូច្នេះព្រះវិញ្ញាណដ៏វិសុទ្ធនឹងមិនចាកចោលនាងខ្ញុំឡើយ។ គ្មានអ្វីធ្វើឲ្យនាង ខ្ញុំប្រព្រឹត្តអំពើអាក្រក់បានទេ"។

ពេលនោះ លោកទេសាភិបាល បានបញ្ជា ឲ្យគេដុតភ្លើងជុំវិញនាង តែភ្លើងនោះ មិនប៉ះពាល់រូបកាយនាងទេ។ ពេលនេះនាងលូស៊ី (ពន្លឺ) ស្រែកឡើងថា ៖"សូមមើល៍! នាងខ្ញុំពិតជាព្រះដំណាក់ នៃព្រះវិញ្ញាណដ៏វិសុទ្ធមែន ព្រះអង្គជួយការពារនាងខ្ញុំមែន!"។

ទីបញ្ចប់ គេយកដាវមួយមកចាក់បេះដូងនាង។ នាងលូស៊ី(ពន្លឺ)ទទួលមរណភាព ក្រោយពីលោកបូជាចារ្យម្នាក់ជូនព្រះកាយ ព្រះគ្រីស្តដល់នាង។ នាងលូស៊ី (ពន្លឺ) ជាគំរូឲ្យយើងគោរពខ្លួនយើង ទុកជាព្រះដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ៕

# ព្រះសហគមន៍ព្រៃប្រស់ទទួលបេក្ខជន៦នាក់ឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក



*បេក្ខនារីទទួលអគ្គសញ្ញាជ្រមុជទឹកពីលោកបូជាចារ្យនៅព្រៃប្រស់។*

លោកបូជាចារ្យ អារ៉ាង ហ្គោហ្វេរណាន់ដូ ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ ព្រៃប្រស់ បានធ្វើអគ្គសញ្ញាជ្រមុជទឹក ជូនបេក្ខជនពេញវ័យចំនួន៦នាក់ ក្នុងរាត្រីបុណ្យចម្លង ឬហៅថាបុណ្យព្រះយេស៊ូ មានព្រះជន្មថ្មីដ៏រុងរឿង។

លោកបូជាចារ្យ ហ្វេរណាន់ដូ បានមានប្រសាសន៍ នៅថ្ងៃបុណ្យចម្លងថា បេក្ខជនទាំង៦នាក់ ដែលបានរៀបចំខ្លួន ទទួលពិធីជ្រមុជទឹកក្នុងថ្ងៃនេះ គឺពួកគាត់នឹងបំពាក់ព្រះយេស៊ូក្នុងខ្លួនរបស់គាត់ និងពួកគាត់ក្លាយជាព្រះកាយ របស់ព្រះគ្រីស្ដតែម្ដង។ លោកបន្ថែមទៀតថា ទោះបីជាយ៉ាងណាក៏ដោយ គ្រីស្ដបរិស័ទត្រូវធ្វើតាមគំរូព្រះយេស៊ូ គឺយើងត្រូវអធិដ្ឋានជាមួយព្រះអង្គ យ៉ាងជិតស្និទ្ធ ហើយទោះបីជា ទទួលអគ្គសញ្ញាជ្រមុជទឹកហើយក៏ដោយ ក៏ពួកគាត់ត្រូវបន្តរៀនអប់រំជំនឿទៀតដែរ។ លោកបូជាចារ្យបានរំឭកថា ចូរឲ្យយើងដឹងថា យើងមានកិត្តិយសដោយសារព្រះជាម្ចាស់ប្រទានឲ្យយើង ហើយយើងជាបុត្រធីតារបស់ព្រះអង្គ។ យើងត្រូវនាំព្រះរាជ្យរបស់ព្រះជាម្ចាស់ មកក្នុងផែនដីនេះ និងសូមឲ្យយើងក្លាយជាបុត្រធីតារបស់ព្រះជាម្ចាស់ យ៉ាងពិតប្រាកដដែលចេះលើកលែងទោសនិងជួយលើកទឹកចិត្តបងប្អូនឯទៀតៗ។

សុខ សីហា អាយុ១៨ ឆ្នាំ មកពីភូមិកោះស្លា ដែលជាព្រះសហគមន៍ថ្មីមួយ មានគ្រីស្ដបរិស័ទប្រមាណ ៩ គ្រួសារប៉ុណ្ណោះ ដែលមានគ្រីស្ដបរិស័ទចំនួន១៨នាក់។ សីហាជាកូនគ្រួសារពុទ្ធបរិស័ទ។ គាត់បានស្គាល់ព្រះសហគមន៍ក្នុងអំឡុង៤ ឆ្នាំមុន ។ ក្នុងឱកាសបុណ្យចម្លងនេះ សីហាបានទទួលអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍ព្រៃប្រស់ ជាមួយបេក្ខជន៥នាក់ផ្សេងទៀត។ យុវជនរូបនេះបានឲ្យដឹងថា "ពីដំបូងខ្ញុំគិតថា ប្ដូរសាសនាដើម្បីរៀនប៉ុណ្ណោះ ប៉ុន្តែពេលខ្ញុំមើលពី របៀបរស់នៅរបស់គ្រីស្ដបរិស័ទប្លែក ចេះសាមគ្គីគ្នា និងជួយអ្នកក្រីក្រ នាំឲ្យខ្ញុំចង់ធ្វើដូចពួកគាត់ដែរ"។

សព្វថ្ងៃសីហា កំពុងស្នាក់នៅ និងសិក្សានៅថ្នាក់ទី១២ នៅមណ្ឌលសិស្សសន្តអូគូស្តាំង ជាមណ្ឌលរបស់ព្រះសហគមន៍កាតូលិក ជួយសិស្សក្រីក្រឲ្យ រៀនសូត្រ។ សីហាបន្ថែមថា " ឪពុកម្ដាយបងប្អូនរបស់ខ្ញុំគាត់អត់ថាអីទេ ព្រោះគាត់ស្គាល់ព្រះសហគមន៍ដែរ។ ហើយពួកគាត់គិតថាល្អ និងចង់ផ្ដល់សេរីភាពដល់ខ្ញុំ"។ ក្នុងនាមជាគ្រីស្ដបរិស័ទថ្មីមួយរូប សីហាបានឲ្យដឹងថា គាត់នឹងព្យាយាមអស់ពីសមត្ថភាព ដើម្បីចូលរួមក្នុងសកម្មភាពព្រះសហគមន៍ ដើម្បីធ្វើជាគំរូដល់អ្នកឯទៀតៗ។

ពិធីអគ្គសញ្ញាជ្រមុជទឹកនេះ ធ្វើឡើងនៅព្រះសហគមន៍ ព្រៃប្រស់ ស្ថិត នៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានអ្នកចូលរួមប្រមាណជាង៥០នាក់ កាលពីយប់ថ្ងៃទី ៤មេសាកន្លងទៅ។ ព្រះសហគមន៍នេះ ជាព្រះសហគមន៍ដែលទើបនឹងបង្កើតថ្មីក្នុងឆ្នាំ២០០៤ ហើយបច្ចុប្បន្នមានគ្រីស្ដបរិស័ទចំនួន ៥០នាក់។ ក្នុងចំណោមបេក្ខជនទាំង៦នាក់ គឺមានតែ២នាក់ទេ ដែលរស់នៅក្នុងព្រះសហគមន៍ព្រៃប្រស់៕

**ដោយកញ្ញា**

# កំពង់ស្ពឺមានព្រះវិហារកាតូលិកជាផ្លូវការណ៍



*លោកអភិបាលលាបប្រេងលើព្រះវិហារថ្មី។ រូបថតៈសុធីរិទ្ធិ*

ព្រះសហគមន៍កាតូលិក កំពង់ស្ពឺ បានបើកសម្ពោធព្រះវិហារថ្មីមួយ ដែលមានឈ្មោះថា សន្តយ៉ូសែប ស្ថិតនៅភូមិពាណិជ្ជកម្ម ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានទទឹងបួនម៉ែត្រ និង បណ្ដោយប្រវែងប្រាំបីម៉ែត្រ នាថ្ងៃទី ១២ មេសានេះ ក្រោមអធិបតីភាពលោកអភិបាល អូលីវីយេ ឝ្មីត អីស្លែរ និងគ្រីស្ដបរិស័ទជាង៦០នាក់ចូលរួម។

ក្នុងឱកាស សម្ពោធព្រះវិហារថ្មី ដែលប្ដូរពីព្រះវិហារឈើ មកថ្មវិញនោះ លោកអភិបាលបានស្នើរសុំឲ្យគ្រីស្ដបរិស័ទនៅទីនោះឲ្យធ្វើជាថ្មដែលមានជីវិតតាមរបៀបគោរពជីវិតដែលមកពីព្រះជាម្ចាស់និងធ្វើជាសាក្សីអំពីព្រះជាម្ចាស់ ហើយជ្រៅជាងនេះទៅទៀត គឺធ្វើតាមព្រះហឫទ័យប្រណីសណ្ដោសរបស់ព្រះជាម្ចាស់ ដោយចេះសម្រុះសម្រួលគ្នា លើកលែងទោសឲ្យគ្នាទៅវិញទៅមក។

ព្រះវិហារសន្តយ៉ូសែប ស្ថិតក្នុងភូមិភាគភ្នំពេញ បានសាងសង់ឡើងនៅចុងឆ្នាំ២០១៤ នៅលើដីជួលមួយកន្លែង ដោយចំណាយថវិកាសរុបចំនួន ៣៩២៥ដុល្លារអាមេរិក ក្រោមការឧបត្ថម្ភពីគ្រីស្ដបរិស័ទនៅប្រទេសវៀតណាម លោកអភិបាល អូលីវីយេ និង សប្បុរសជនគ្រីស្ដបរិស័ទដទៃទៀត ព្រមទាំងការជួយជ្រោមជ្រែងផ្នែកកម្លាំងពលកម្ម របស់គ្រីស្ដបរិស័ទ និងពុទ្ធបរិស័ទក្នុងភូមិផងដែរ។

ព្រះសហគមន៍ កាតូលិកកំពង់ស្ពឺ បានចាប់កំណើតឡើងក្នុងឆ្នាំ២០០៣ ដោយមានគ្រីស្ដបរិស័ទ ៦ គ្រួសារ បានជួបជុំគ្នាអធិដ្ឋាន នៅក្នុងហាងកាហ្វេមួយកន្លែង ហើយក្រោយមកមានគ្រីស្ដបរិស័ទម្នាក់បានជួលដីនិងសង់ផ្ទះឈើមួយ ដើម្បីអធិដ្ឋាន។ បច្ចុប្បន្ន ព្រះសហគមន៍មួយនេះមានគ្រីស្ដបរិស័ទចំនួន ២២ គ្រួសារ៕

**ដោយដាលីស**

# មណ្ឌលកុមារពិការអារូពេ ទទួលសាលាខ្នាតអន្តរជាតិពីមូលនិធិ Real Madrid



*ក្រុមរៀលម៉ាឌ្រីត ថតរូបអនុស្សាវរីយ៍ជាមួយក្រុមកីឡាអារូពេ។*

មណ្ឌលកុមារពិការ អារូពេ របស់ព្រះសហគមន៍កាតូលិកស្ថិតក្នុងខេត្តបាត់ដំបង នឹងទទួលបានសាលារៀនបណ្ដុះបណ្ដាល ផ្នែកកីឡាខ្នាតអន្តរជាតិមួយក្នុងពេល ប៉ុន្មានឆ្នាំខាងមុខទៀត នេះបើតាមប្រសាសន៍របស់លោកអភិបាល អេនរីគេ ហ្វីការេដូ ទទួលខុសត្រូវ ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

លោកអភិបាល អេនរីគេបានមានប្រសាសន៍កាលពីថ្ងៃទី ៥ មេសា ថា រយៈពេល ៥ឆ្នាំទៀត យើងនឹងប្រែក្លាយមណ្ឌលអារូពេ ទៅជាសាលាខ្នាតអន្តរជាតិទីមួយ លើពិភពលោកផងដែរ ដែលភ្ជាប់កីឡា និង សង្គមសម្រាប់ជនពិការ។ ជាមួយគ្នានេះ សាលានេះមានគោលដៅលើកកម្ពស់វិស័យអប់រំនៅកម្ពុជា តាមរយៈការបញ្ជ្រាបវិស័យកីឡាជាមួយផងដែរ។

ការអះអាងនេះ បានធ្វើឡើងក្រោយពេលមូលនិធិ រៀលម៉ាឌ្រីដ (Real Madrid) និងអង្គការសាអ៊ូសេ (SolidaridadAyuda y Union Crean Esperanza (SAUCE)) ដែលមានមូលដ្ឋាន នៅខេត្តបាត់ដំបង បានចុះអនុស្សារណៈ នៃការយោគយល់គ្នាមួយ ដើម្បីធ្វើការសាងសង់មណ្ឌលស្នាក់នៅ និងសាលាបណ្ដុះបណ្ដាលកីឡា ខ្នាតអន្តរជាតិមួយ សម្រាប់ជនពិការ។

ពិធីចុះហត្ថលេខា ត្រូវបានធ្វើឡើងរវាង លោក ហ្លូរិនទីណូ ពែរ៉េស (Florentino Perez) ប្រធានក្លឹបរៀលម៉ាឌ្រីដ និងលោក អេនរីគេហ្វីការេដូ (Enrique Figaredo) ស្ថាបនិកអង្គការសាអ៊ូសេ (SAUCE) ។ នេះបើតាមការបញ្ជាក់ របស់គេហទំព័រផ្លូវការក្លឹបរៀលម៉ាឌ្រីដ ជាភាសាអេស្ប៉ាញនាថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៥នេះ។

ក្រោមជំនួយរបស់មូលនិធិ រៀលម៉ាឌ្រីដ សាលាដែលមានមូលដ្ឋាន នៅខេត្តបាត់ដំបងនោះ នឹងក្លាយជាមណ្ឌលស្នាក់នៅ និង ជាសាលាបណ្ដុះបណ្ដាលកីឡាខ្នាតអន្តរជាតិទីមួយលើពិភពលោកផងដែរ ដែលមានបង្វឹកកីឡាគ្រប់ប្រភេទ សម្រាប់ជនពិការនិងមិនពិការនៅកម្ពុជា ព្រមទាំងមានគ្រូហ្វឹកហ្វឺនពីបរទេស ផ្នែកកីឡាមកបង្រៀនផងដែរ។ មណ្ឌលនេះនឹងទទួលកុមារពីអាយុ ៦ ទៅ ១៧ឆ្នាំ ដោយឲ្យពួកគេស្នាក់នៅមានអាហារហូបចុក និងផ្ដល់ការឧបត្ថម្ភដល់ការសិក្សានៅសាលារដ្ឋ។

លោកអភិបាល បានឲ្យដឹងដែរថា កាលពី ៤ឆ្នាំមុន ក្រុមរៀលម៉ាឌ្រីដ បានមកលេង និងសួរសុខទុក្ខយើង នៅមណ្ឌលអារូពេ ហើយយើងបានស្នើសុំគ្រូបង្វឹកកីឡា មកជួយបង្ហាត់កីឡាដល់ក្រុមកុមារពិការយើង ដើម្បីជួយយើងឲ្យមានការរៀបចំល្អប្រសើរជាងមុន។ លោកបន្តថា "ក្រុមរៀលម៉ាឌ្រីដ បានចាប់អារម្មណ៍ចំពោះរបៀប និង សកម្មភាពរបស់យើង (មណ្ឌលអារ៉ូពេ )ដែលមានគម្រោងសកម្មភាពខុសពីកន្លែងផ្សេង គឺយើងបានផ្ដល់ឱកាសសម្រាប់ទាំងមនុស្សពិការ និងមនុស្សមិនពិការដើម្បីហាត់ប្រាណ និងលេងកីឡាជាមួយគ្នា"។

បច្ចុប្បន្ននេះ មណ្ឌលកុមារពិការអារូពេនៅ ខេត្តបាត់ដំបង មានកុមារប្រមាណ១៦០នាក់ ដែលក្នុងនោះ ៥៩នាក់ជាជនពិការកាយសម្បទា។

អង្គការ សាអ៊ូសេ ត្រូវបានបង្កើតឡើងដោយលោក អេនរីគេ ហ្វីការេដូ ជនជាតិអេស្ប៉ាញ ដែលជាបព្វជិតសាសនាគ្រីស្តម្នាក់ដ៏ល្បីល្បាញ ។ លោកបានចូលមកកាន់កម្ពុជាតាំងពីឆ្នាំ១៩៨៥មកម្ល៉េះ ហើយសកម្មភាពសប្បុរសធម៌ របស់លោកត្រូវបានគេទទួលស្គាល់នៅទូទាំងពិភពលោក៕

**ដោយឡុង សម្ផស្ស**

# បាត់ដំបងធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបេក្ខជនចំនួន១៨រូប

នៅក្នុងឱកាស បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (បុណ្យចម្លង) ឆ្នាំនេះ នៅព្រះវិហារ ព្រះជាម្ចាស់ លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ស្ថិតនៅស្រុកស្វាយប៉ោ ខេត្តបាត់ដំបង មានបងប្អូនចំនួន១៨ នាក់ បានទទួល អគ្គសញ្ញាជ្រមុជទឹក ក្រោមអធិបតីភាពលោក រេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងព្រមទាំងមានបព្វជិត បព្វជិតា និង បងប្អូនគ្រីស្តបរិស័ទ ចំនួនប្រមាណជាង ៥០០នាក់ ។

លោកអភិបាលអេនរីគេ បានមានប្រសាសន៍ថា ក្នុងពិធីបុណ្យចម្លងព្រះសហគមន៍យើង បានទទួលជាថ្មីម្ដងទៀតនូវសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ ក្នុងព្រះហឫទ័យរបស់ព្រះអង្គ ដែលជួយជំរុញយើងឲ្យទៅមុខទៀត។ ពេលនេះយើងរំលឹកអំពីពេលវេលាដែលព្រះយេស៊ូទទួលការលំបាក និងមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូធ្វើតាមបំណង របស់ព្រះជាម្ចាស់ ដែលបានបង្ហាញមាគ៌ារបស់ព្រះជាម្ចាស់ ដោយឲ្យ យើងចេះបន្ទាបខ្លួន ស្រឡាញ់ និង លើកទឹកចិត្តបងប្អូន។ យើងទទួលស្គាល់ថា នៅលើលោកនេះ អំពើអាក្រក់ អំពើឃោរឃៅ មិនមានអំណាចអ្វី ឈ្នះសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ឡើយ ។ យើងដឹងហើយថា ជីវិតរបស់ព្រះយេស៊ូផ្ទាល់ គង់នៅជាមួយយើង ដើម្បីឲ្យយើងមានកម្លាំងដើរតាមព្រះអង្គ ។

លោកអភិបាល បានសង្កត់ធ្ងន់ សេចក្ដីស្រឡាញ់ មានអំណាចឈ្នះអំពើអាក្រក់ និងសេចក្ដីស្រឡាញ់ដែលយើងបានទទួលនោះ គឺមានជាប់រហូតមកដល់សព្វថ្ងៃ។ សេចក្ដីស្រឡាញ់នោះគឺយើងបានទទួលតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ស្ថិតនៅក្នុងដួងចិត្ត និងតាមរយៈបងប្អូនយើង ដែលធ្វើតាមព្រះហឫទ័យព្រះយេស៊ូ ដែលបានទទួលពិធីជ្រមុជទឹក នាឱកាសនេះ និងនាំឲ្យយើងមានកម្លាំង ។ វត្តមាននៃសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ និងវត្តមានរបស់ព្រះយេស៊ូ ដែលគង់នៅជាមួយយើង នាំឲ្យយើងមានកម្លាំង ដោយអាចនាយើងឲ្យដើរទៅមុខតាមមាគ៌ារបស់ព្រះអង្គ ។

លោកអភិបាល បានរំឭកគ្រីស្តបរិស័ទទាំងអស់ឲ្យចេះសង្កេត និងរៀនអំពីព្រះហឫទ័យរបស់ព្រះយេស៊ូ ដើម្បីឲ្យចិត្តរបស់ខ្លួន ប្រព្រឹត្តដូចព្រះយេស៊ូ គឺដូចដែលព្រះយេស៊ូបានប្រព្រឹត្តតាមព្រះហឫទ័យ របស់ព្រះជាម្ចាស់ ដោយមិនតាមចិត្តរបស់ឯងផ្ទាល់ ។

មានចំណាប់អារម្មណ៍ នាឱកាសនោះ កញ្ញា ញ៉ាញ់ ពាន អាយុ១៩ឆ្នាំ មកពីភូមិតាហែន បានឲ្យដឹងថា នាងមានអំណរសប្បាយ យ៉ាងក្រៃលែង ដែល បានទទួលអគ្គសញ្ញាជ្រមុជទឹក នៅថ្ងៃនេះ អស់រយៈពេល៣ឆ្នាំហើយ ដែលនាងបានស្វែងយល់ អំពីជំនឿនៅព្រះសហគមន៍កាតូលិក។ តាមរយៈការស្វែងយល់ជំនឿ ធ្វើឲ្យនាងមានជំនឿកាន់តែរឹងមាំទៅលើព្រះជាម្ចាស់ ។

នៅក្នុងឱកាស បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (បុណ្យចម្លង)២០១៥នេះ នៅព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានបងប្អូនចំនួន ៦៤ នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក ក្លាយជាគ្រីស្តបរិស័ទពេញលេញ។ នៅក្នុងព្រះសហគមន៍កាតូលិក បេក្ខជនជាមនុស្សពេញវ័យទាំងអស់ ដែលមានបំណងស្វែងរកយល់ពីជំនឿលើព្រះយេស៊ូ មុនទទួលអគ្គសញ្ញាជ្រមុជទឹក គឺត្រូវទទួលអប់រំជំនឿយ៉ាងតិច៣ឆ្នាំដែរ តាមកម្មវិធីអប់រំជំនឿនៃព្រះសហគមន៍កាតូលិក៕

**ដោយឡុង សម្ផស្ស**

# ព្រះសហគមន៍ប៊ូស្រាមានគ្រីស្តបរិស័ទបន្ថែមទៀត



គ្រីស្តបរិស័ទ នៅព្រះសហគមន៍ប៊ូស្រា នៃខេត្តមណ្ឌលគិរី ដែលជាព្រះសហគន៍តូចមួយ នៅតំបន់ភាគឦសាន្តប្រទេសរីករាយទទួលយុវនារីម្នាក់ឲ្យទទួលពិធីជ្រមុជទឹកក្នុងពេលបុណ្យចម្លងនេះ កាលពីថ្ងៃទី៥មេសាកន្លងទៅ ដោយមានលោកបូជាចារ្យសាឡាសាណូយ៉ូហានយេស៊ូ ជាប្រធានអធិបតី។

ក្នុងធម្មទេសនា លោកបូជាចារ្យសាឡាសាណូយ៉ូហានយេស៊ូ បានមានប្រសាសន៍ថា៖ ពេលដែលយើងទទួលអគ្គសញ្ញា ជ្រមុជទឹកនោះមានន័យថា យើងបានរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង។នេះជាសញ្ញាមួយ ដើម្បីឲ្យយើងមានសេចក្តីសង្ឃឹមនៅក្នុងជីវិតថា យើងនិងមានជីវិតរស់ឡើងវិញ ដូចព្រះយេស៊ូដែរ។ លោកបូជាចារ្យបានបន្តថា ៖ យើងត្រូវប្រកាសជំនឿរបស់យើង រួមជាមួយសកម្មភាពរបស់យើង ដោយហេតុនេះសូមកុំឲ្យយើងនិយាយតែមាត់ត្រូវតែប្រកាសជំនឿរបស់យើងដោយចេញពីចិត្ត និងសកម្មភាព។

លោកបូជាចារ្យក៏សូមដាស់តឿនដល់គ្រីស្តបរិស័ទផងដែរថា ៖ ក្នុងនាមយើងជាគ្រីស្តបរិស័ទ យើងត្រូវដឹងថា ព្រះយេស៊ូពិតជាស្រលាញ់យើងពិតមែន ដោយសុខចិត្តបូជាព្រះជន្មដើម្បីរំដោះបាបឲ្យយើង។

កញ្ញា ចាត ស្រីណា វ័យ១៨ឆ្នាំជាបេក្ខនារី ដែលបានទទួលពិធីជ្រមុជទឹកនៅព្រះសហគមន៍កាតូលិកប៊ូស្រា បានប្រាប់ឲ្យដឹងថា ៖ កញ្ញាពិតជាមានអារម្មណ៍ថារំភើប ដូចជាបានកើតម្តងទៀត នៅពេលដែលលោកបូជាចារ្យកំពុងធ្វើពិធីជ្រមុជទឹក។ កញ្ញាបន្តថា៖ អស់រយៈពេល៣ឆ្នាំ ដែលកញ្ញារង់ចាំដើម្បីក្លាយជាគ្រីស្តបរិស័ទ ព្រមទាំងមានឱកាស បានទទួលព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ធ្វើឲ្យស្រីណា មានអារម្មណ៍ថា "ពិតមែនខ្ញុំបានទទួលព្រះយេស៊ូ ដាក់ក្នុងចិត្ត ហើយខ្ញុំមានជីវិតថ្មីរួមជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ជាពិសេស ខ្ញុំបានក្លាយទៅជាសមាជិក នៃមហាគ្រួសារដ៏ធំរបស់ព្រះសហគមន៍កាតូលិក"។

ស្រីណា បន្តយ៉ាងមុតមាំថា និងព្យាយាមរស់នៅតាមសេចក្តីត្រឹមត្រូវស្មោះត្រង់ ចូលរួមជួយបន្តជំនឿដល់ក្មេងជំនាន់ក្រោយ អធិដ្ឋាន និងចែករំលែកសេចក្តីស្រលាញ់ទៅអ្នកដទៃ។

កម្មវិធីជ្រមុជទឹកនេះបានធ្វើឡើងនៅព្រះវិហារព្រះយេស៊ូប្រសូត ជាមនុស្សដែលមានទីតាំងស្ថិតនៅ ក្នុងភូមិឡាំម៉េះ ឃុំប៊ូស្រា ស្រុកពេជ្រដាខេត្តមណ្ឌលគិរី ដែលមានអ្នកចូលរួមប្រមាណជាង២០០នាក់។

លោក ព្រី ត្រៃ អាយុ៦៦ឆ្នាំ ជាគណកម្មាការ នៅព្រះសហគមន៍កាតូលិកប៊ូស្រា បានឲ្យដឹងថា នៅទីនេះមុនដំបូង គឺមានគ្រីស្តបរិស័ទចំនួន១៥នាក់ជាជនជាតិភាគតិចព្នង ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក នៅប្រទេសវៀតណាម។

លោកបានរំឭកថា ក្នុងសម័យសង្គ្រាមវៀតណាម ជាមួយអាមេរិក និងនៅសម័យប៉ុលពត នៅខេត្តមណ្ឌលគិរី មានជនជាតិភាគតិចជាច្រើនបានរត់គៀសខ្លួន ទៅប្រទេសវៀតណាម ដើម្បីសុំសិទ្ធិជ្រកកោនពីបងប្អូននៅប្រទេសនោះ។ ក្រោយមកមានមួយចំនួន បានទទួលអគ្គសញ្ញាជ្រមុជទឹកនៅទីនោះ ហើយបានវិលមកកម្ពុជាវិញ រស់នៅក្នុងភូមិប៊ូស្រា និង ខ្លះទៀតនៅដាក់ដាំ។ បច្ចុប្បន្នព្រះសហគមន៍ប៊ូស្រា មានគ្រីស្តបរិស័ទប្រមាណជិត ៧០នាក់ ជាជនជាតិព្នងមានទាំងមនុស្សចាស់ និងយុវជន៕

**ដោយរឿន ស្រីម៉ាច**

# គ្រីស្តបរិស័ទទទួលជីវិតថ្មីពីអគ្គសញ្ញាជ្រមុជទឹក

ព្រះសហគមន៍ កំពង់ចាមក្រុង បានទទួលបេក្ខជនចំនួន ៦នាក់ឲ្យទទួលអគ្គសញ្ញជ្រមុជទឹក ក្នុងឱកាសបុណ្យចម្លង ឬបុណ្យព្រះយេស៊ូប្រសូត កាលពីថ្ងៃទី ០៥ មេសាកន្លងទៅ នៅព្រះសហគមន៍កាតូលិក កំពង់ចាមក្រុងស្ថិតនៅ ភូមិទី១ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។

លោក ហ្វ្រង់ស័រ អេមេល្យដាល ជាបូជាចារ្យទទួលខុសត្រូវ ព្រះសហគមន៍កំពង់ចាមក្រុង បានឲ្យដឹងថា៖ បច្ចុប្បន្ន បុណ្យចម្លងបានផ្តល់អត្ថន័យសំខាន់ណាស់ សម្រាប់ជីវិតជាគ្រីស្តបរិស័ទរបស់យើងម្នាក់ៗ គឺបានន័យថា យើងត្រូវរួមស្លាប់ រួមរស់ជាមួយព្រះយេស៊ូគ្រីស្ត។ព្រះយេស៊ូបានសោយទិវង្គតទៅ ហើយព្រះអង្គបានរស់ឡើងវិញដ៏រុងរឿង សម្រាប់យើងទាំងអស់គ្នា ដូច្នេះយើងក៏បានស្លាប់ ហើយក៏មានជីវិតថ្មី ជាមួយព្រះអង្គដែរ។ បូជាចារ្យរូបនេះបានបន្តទៀតថា យើងមានជីវិតថ្មីមានន័យថាយើងបានកែប្រែ របៀបរស់នៅរបស់យើង លះបង់អំពើបាបដែលយើងធ្លាប់បានប្រព្រឹត្ត លះបង់ការភ័យខ្លាច និងជឿទុកចិត្តលើព្រះជាម្ចាស់ តែមួយព្រះអង្គ។

យុវជនធឿន វិធៃ ជាបេក្ខជន មកពីព្រះសហគមន៍កាតូលិកភូមិថ្មី បានឲ្យដឹងថា៖ ថ្ងៃបុណ្យចម្លងនេះហើយដែលគាត់ទទឹងរង់ចាំ ដើម្បីឲ្យគាត់បានចូលរួមជាមួយគ្រួសារមួយ ដ៏ធំពោរពេញដោយ សេចក្តីស្រលាញ់នេះ។ វិធៃបន្តថា សកម្មភាពរបស់ព្រះសហគមន៍ បានទាក់ទាញចិត្តរបស់គាត់ដែលមានដូចជាព្រះសហគមន៍ចេះផ្តល់សេចក្តីស្រលាញ់ឲ្យគ្នាទៅវិញទៅមក ជាពិសេសនោះគឺព្រះសហគមន៍ មានភាពជិតស្និតជាមួយអ្នកក្រីក្រ និងអ្នកគ្មានទីពឹង។

គាត់បានបន្តទៀតថា គាត់នឹងបំពេញតួនាទីជាគ្រីស្តបរិស័ទមួយរូបដ៏ល្អ សម្រាប់ព្រះសហគមន៍ និងធ្វើជាមនុស្ស ដែលមានប្រយោជន៍សម្រាប់សង្គមជាតិ និងអ្នកក្រីក្រ។

ក្នុងឱកាសបុណ្យចម្លង ឆ្នាំ២០១៥ នេះ នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម មានបេក្ខជនចំនួន ៥០នាក់ ដែលបានទទួលពិធីជ្រមុជទឹក។ ព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម មានគ្រីស្តបរិស័ទសរុបប្រមាណ ៣០០០នាក់ និងគ្របដណ្តប់លើខេត្តចំនួន៨ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី៕

# អាគារថ្មីជាបេះដូងនៃមណ្ឌលសកម្មភាពកំពតកែប



*អាគារមណ្ឌលសកម្មភាពកំពតកែបដែលទើបនឹងសាងសង់រួច ។ រូបភាពៈ*

មណ្ឌលសកម្មភាពកំពតកែបនឹងមានសកម្មភាព ជាច្រើនបន្ថែមទៀត បន្ទាប់ពីអាគារមួយខ្នង កម្ពស់ពីរជាន់ថ្មីនឹងត្រូវសម្ពោធនាពេលបន្តិចទៀតនេះ។

លោក យ៉ាំងលូកា បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពនេះ មានប្រសាសន៍ថា កំពតជាបេះដូង នៃមណ្ឌលសកម្មភាពកំពតកែប ដែលមានប្រាំកន្លែង ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ព្រះសហគមន៍មិនទាន់មានកន្លែងសម្រាប់ជួបជុំគ្នានៅឡើយទេ ។ លោកបន្តថា សព្វថ្ងៃយើងធ្វើសកម្មភាពជួបជុំគ្នាច្រើននៅជុំគិរី ដែលមានកន្លែងធំល្មម។ ដូច្នេះលោកអភិបាល អូលីវីយេ បានស្នើឲ្យយើងបង្កើតកន្លែងដើម្បីជួបជុំ លក្ខណៈទ្រង់ទ្រាយធំនៅកំពត ព្រោះទីនេះជាបេះដូងនៃមណ្ឌលសកម្មភាពនេះ។

មណ្ឌលសកម្មភាពកំពតកែបមានព្រះសហគមន៍ចំនួន៥ គឺកំពត ព្រែកប្រស់ ជុំគិរី កោះស្លា និងកែប។

លោកបូជាចារ្យបន្តថា តាមរយៈអគារថ្មីនេះ"យើងនឹងមានសកម្មភាពដូចជា សិក្ខាសាលាយុវជន សង្គហៈ ពិធីបុណ្យ ពិធីជំហានទីមួយរួមជាមួយគ្នា ដើម្បីយើងយល់ថា យើងជាបងប្អូន ដែលនៅក្នុងមណ្ឌលសកម្មភាពតែមួយ ទោះបីព្រះសហគមន៍នៅកន្លែងផ្សេងៗ"។

លោកបូជាចារ្យ យ៉ាំងលូកាឲ្យដឹងថា បន្ថែមលើសនេះ នៅទីនេះយើងមានកូនសិស្សមកពីតំបន់ឆ្ងាយៗមកស្នាក់នៅនិងរៀនសូត្រ ហើយយើងនៅទីនេះគឺជាកន្លែងរៀបចំពិធីបុណ្យ សៀវភៅអប់រំជំនឿ សម្ភារគណនេយ្យ និង រដ្ឋបាល និង ផ្នែកអប់រំសោលាមត្តេយ្យដែរ អប់រំសុខភាព និងពិនិត្យជំងឺ។ អ្វីៗទាំងអស់យើងធ្វើនៅកំពត ព្រោះនៅទីនេះយើងមាន ភ្លើង មានបុគ្គលិកដែលមានសមត្ថភាព។ ហើយព្រះសហគមន៍នានា ក្នុងតំបន់នេះដូចជាប្រើសេវាកម្មម៉្យាង ដែលយើងមាននៅទីនេះ។

អាគារមណ្ឌលសកម្មភាព កំពតកែប នឹងបើកឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១១ ខែឧសភានេះ។ អាគារនេះមានកម្ពស់២ជាន់ ដែលផ្នែកខាងក្រោម គឺជាការិយាល័យនៃមណ្ឌលសកម្មភាព ផ្នែកខាងលើ គឺជាបន្ទប់សាលប្រជុំ ដែលអាចផ្ទុកមនុស្សជិត២០០នាក់។

ជាមួយគ្នានេះដែរ លោកបូជាចារ្យបានរំពឹងថា មណ្ឌលសកម្មភាពនេះនឹងមានបងប្អូនឯទៀតៗ ចូលរួមកាន់តែច្រើន ដោយនឹងមានបង្កើតក្រុមជំទង់កាយឫទ្ធិផងដែរ៕

**ដោយកញ្ញា**

# ពិធីលាងជើងរំឭកគ្រីស្តបរិស័ទអំពីការបម្រើគ្នា



*លោកអភិបាលលាងជើងជូនគ្រីស្តបរិស័ទ ។រូបថតៈ លីហៀង*

គ្រីស្តបរិស័ទជាង៦០០នាក់ បានចូលរួម អភិបូជាកាលពីថ្ងៃព្រហស្បត្តិ៍ពិសិដ្ឋ ជាថ្ងៃដែលរំឭកអំពីព្រះយេស៊ូជប់លៀងចុងក្រោយ និងលាងជើងដល់ក្រុមសាវ័ក១២រូប ក្រោមអធិបតីភាព របស់លោកអភិបាល ភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតអីស្លែរ និង លោកបូជាចារ្យ នីកុន ប្រាស៊ូតសែងចាន់ ជាបូជាចារ្យជំនួយការនៃមណ្ឌលសកម្មភាពមេគង្គ នាល្ងាចថ្ងៃទី០២ មេសានេះ នៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ៉(ចំប៉ា) ក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាល។

ក្នុងធម្មទេសនា លោកអភិបាលបានមានប្រសាសន៍ថា ៖នេះជាឱកាសមួយ ជួយឲ្យយើងរិះគិតអំពីព្រះបន្ទូលមរតក៏របស់ព្រះយេស៊ូគឺ "សូមអ្នករាល់គ្នាត្រូវតែលាងជើងឲ្យគ្នាទៅវិញ ទៅមក ដូចខ្ញុំបានធ្វើជាគំរូឲ្យអ្នករាល់គ្នាប្រព្រឹត្ត" ហេតុនេះហើយ ជីវិតរបស់យើងទៅជាអ្នកបម្រើ ដូចព្រះយេស៊ូបានបម្រើយើង។

លោកអភិបាល អូលីវីយេបន្តថា៖ យើងធ្វើដូចនេះ ដើម្បីបង្ហាញថា ការលាងជើងនេះ មិនមែនជាល្ខោនមួយទេ តែគឺជាពេលវេលាមួយ ដើម្បីឲ្យយើងទទួលកម្លាំង ដោយបម្រើគ្នាទៅវិញទៅមកពេញមួយឆ្នាំ ជារៀងរាល់ថ្ងៃ និងពេលយើងចូលអភិបូជាយើងត្រូវការនឹកឃើញកាយវិការទាំងអស់របស់ព្រះយេស៊ូដែលបូជាជីវិត ដោយស្រឡាញ់យើង។ លោកអភិបាលបន្ថែមថា៖ ហេតុនេះហើយ ទើបគ្រីស្តបរិស័ទ ចូលរួមថ្វាយអភិបូជា ដែលជាពិធីកំពូលនៃជីវិត។ លោកអភិបាលបញ្ជាក់ថា "ដោយសារយើងទទួលកម្លាំង ហើយថ្វាយជីវិតរបស់យើងទៅព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិតរបស់យើង ដោយសារយើងទទួលសមត្ថភាព និងជំនឿពីព្រះជាម្ចាស់ឲ្យស្រឡាញ់គ្នាទៅវិញទៅមក" ។

មុនពេលបញ្ចប់អភិបូជា លោកអភិបាល បានលាងជើងជូនគ្រីស្តបរិស័ទចំនួន ១២ នាក់តំណាងឲ្យគ្រីស្តទូតទាំង ១២នាក់ ក្រោយមកអ្នកតំណាងគ្រីស្តទូតនេះ បានចេញទៅលាងជើង ឲ្យគ្រីស្តបរិស័ទឯទៀតៗ ដើម្បីជាសញ្ញាថាគ្រីស្តបរិស័ទ សុខចិត្តបម្រើគ្នាទៅវិញទៅមក។

យុវនារី សុខ ធីតាបានឲ្យដឹងថា៖ "កាយវិការ នៃការលាងជើងនេះ ពិតជាបានជួយឲ្យជំនឿខ្ញុំរឹងមាំ ដោយបង្ហាញឲ្យខ្ញុំយល់ថា ព្រះយេស៊ូបានបង្ហាញសេចក្ដីស្រឡាញ់ដ៏លើសលប់របស់ទ្រង់ ដោយបន្ទាបខ្លួនមកលាងជើងឲ្យក្រុមគ្រីស្តទូត ក៏ដូចជាពួកយើងដែលជាអ្នកទន់ទាប និងឲ្យខ្ញុំយកគំរូតាម ដើម្បីឲ្យក្លាយជាគ្រីស្តបរិស័ទ ដែលពោរពេញដោយសេក្ដីស្រឡាញ់ និងហ៊ានបន្ទាបខ្លួនក្នុងគ្រប់កិច្ចការដោយជួយព្រះសហគមន៍ និង ខិតខំស្រឡាញ់ជនពិការ និងចាស់ៗ ដើម្បីឲ្យពួកគាត់មានកម្លាំងចិត្តតស៊ូរស់តទៅទៀត"។

រីឯលោកបូជាចារ្យ នីកុន ប្រាស៊ូតសែងចាន់ បានមានប្រសាសន៍ផ្ដាំផ្ញើរដល់យុវជនយុវនារី និងកុមារទាំងអស់នៅពេលត្រលប់ទៅផ្ទះវិញ សូមលាងជើងឲ្យឪពុកម្ដាយ ដើម្បីបង្ហាញសេចក្ដីស្រឡាញ់ និង ដឹងគុណដល់ឪពុកម្ដាយដែលតែងតែស្រឡាញ់ និងថ្នាក់ថ្នម។ លោកមានប្រសាសន៍ដូច្នេះ ព្រោះយល់ឃើញថាយុវជន និងក្មេងៗបច្ចុប្បន្ននេះ ស្រឡាញ់មិត្តភ័ក្ត្រច្រើនជាងអ្នកផ្ទះ ហើយនេះក៏ជាឱកាសមួយដើម្បីទទួលពរពីពួកគាត់ ខណៈដែលគាត់នៅមានជីវិត ប្រសើរជាងពេលពួកគាត់លាចាកលោកនេះទៅ។

**ដោយដាលីស**

# ដុនបូស្កូកែបបើកជំនាញថ្មីផ្នែកសិល្បៈនៃការទំនាក់ទំនងសង្គម



យុវជនសិក្សាផ្នែកដន្ត្រី ។រូបថតៈ KG

ជំនាញសិល្បៈ នៃការទំនាក់ទំនងសង្គម (Art of Communication) ជាជំនាញមួយថ្មីក្នុងផ្នែកសិល្បៈ ដែលសាលាបច្ចេកទេស ដុនបូស្កូកែប បានបង្កើតឡើង ដើម្បីបំពេញនូវសេចក្តីត្រូវការផ្នែកសង្គម។

លោកបូជាចារ្យ រ៉ូដាស អាល់បេរ៉ូ ហៅសំណាង ដែលជាអធិការនៃសាលានេះ បានមានប្រសាសន៍ថា នេះជាមុខវិជ្ជាថ្មី ដែលយើងបានរៀបចំបង្កើតឡើងកាលឆ្នាំ២០១៣។ លោកបន្តថា "សាលាបានបង្កើតមុខជំនាញនេះឡើង ដោយសារមនុស្សបច្ចុប្បន្នគិតអំពីរបៀប Design (រចនា) ធ្វើ Logo (ផ្លាកសញ្ញា) ដើម្បីធ្វើការផ្សព្វផ្សាយទីផ្សារ និងរកពាណិជ្ជកម្មឲ្យបានស្អាតៗ និងទាក់ទាញដែលនេះជាជំនាញមួយខុសពីជំនាញទំនាក់ទំនងសង្គម ដែលយើងបង្រៀនអំពីពត៌មាន និង IT(ពត៌មានវិទ្យា)"។ លោកបន្តថា អ្នករៀនIT គេមិនមានគំនិតអំពីសិល្បៈ ដូច្នេះមិនសូវចាប់អារម្មណ៍អំពីអ្វីស្អាត គេថា ក គឺក ហើយថតទុកនិងវាយទុក។

លោកបូជាចារ្យសំណាង ពន្យល់ថា សិល្បៈមានន័យថា គិតអំពីអ្វីដែលស្អាត ហើយសិល្បៈជាសំខាន់ក្នុងប្រវត្តិសាស្ត្រជនជាតិខ្មែរ ហើយបើយើងមើលគ្រប់កន្លែង តាមប្រាសាទមានក្បាច់ បែបសិល្បៈស្អាតៗ។ ម្យ៉ាងទៀតសិល្បៈ អាចផ្តល់អត្ថន័យច្រើនសម្រាប់ការអប់រំ។ អ្នកដែលមានសិល្បៈមានចំណុចខុសគ្នា និងធ្វើការងារនៅក្នុងសហគមន៍ស្រួលជាង និងចេះគិតពិចារណាបែបសិល្បៈ។

លោកសំណាង បានបន្ថែមថាក្នុងឆ្នាំសិក្សាដំបូង មានសិស្សតិចតួចទេមកដាក់ពាក្យចូលរៀន ព្រោះយុវជនគិតថា សិល្បៈគឺមានតែរាំ ច្រៀង។ ប៉ុន្តែ ក្នុងការបង្រៀនរបស់យើងមានដូចជា មុខវិជ្ជារចនាគេហទំព័រវេបសាយតាមកុំព្យូទ័រមុខវិជ្ជាតន្ត្រីសម័យ មុខវិជ្ជារបាំ និងមុខវិជ្ជាភាសាអង់គ្លេស ដែលអាចជួយឲ្យយុវជន ចេះអំពីសិល្បៈ និងឲ្យគេងាយស្រួលរកការងារធ្វើ។

យុវជន ហ៊ុំ លឿន អាយុ២១ឆ្នាំ រៀននៅឆ្នាំទី១ឲ្យដឹងថា "រៀននៅទីនេះ គឺផ្នែកនីមួយៗមានការគ្រប់គ្រងល្អ និងបណ្តុះបណ្តាលនៃការរៀនល្អដូចគ្នា ហើយខ្ញុំជ្រើសរើសផ្នែកសិល្បៈនេះ ព្រោះវាមានខាងតន្ត្រី Design និងគំនូរជាដើម ជាចំណូលចិត្តរបស់ខ្ញុំ"។

ហ៊ុំ លឿន បានឲ្យដឹងទៀតថា ទោះបីជាគាត់មិនសូវដឹងថា ពេលរៀនចប់ នឹងទទួលបានការងារអ្វីក៏ដោយ តែយុវជនរូបនេះ នៅតែផ្តោតសំខាន់លើសមត្ថភាពរបស់ខ្លួនក្នុងការសិក្សា ដែលផ្តោតសំខាន់លើផ្នែករចនា។

ង៉ែត តូនឹប អាយុ២២ឆ្នាំជានិស្សិតឆ្នាំទី២បាននិយាយថា "ម្តាយឪពុកខ្ញុំគាត់សួរខ្ញុំថា ចុះរៀនចប់ផ្នែកហ្នឹងធ្វើការងារអីដែរទៅ។ ខ្ញុំគ្រាន់តែថា បើចេញទៅមិនដែលអត់ការងារធ្វើនោះទេ។ ខ្ញុំគិតថា អ្វីដែលយើងរៀន គឺមិនអត់ប្រយោជន៍ទេ ឲ្យតែយើងចេះទ្រាំនិងតស៊ូទៅបានហើយ។ នៅនេះខ្ញុំរៀនកុំព្យូទ័រខាងDesign ដូច្នេះខ្ញុំមានសង្ឃឹមច្រើនខាងនេះ និងខាងភ្លេងព្រោះខ្ញុំបានហ្វឹកហាត់មួយចំនួនជាមួយលោកគ្រូ(ភ្លេង) នៅតាមកម្មវិធីផ្សេងៗ ដូចជាពិធីការ ជប់លៀងក្នុងសាលាអីដែរ"។

លោកបូជាចារ្យ សំណាង ឲ្យដឹងទៀតថា មុខជំនាញសិល្បៈនៃការទំនាក់ទំនងសង្គមនេះ ត្រូវបានបង្រៀនរយៈពេល២ឆ្នាំ។ បច្ចុប្បន្ននេះ ផ្នែកសិល្បៈនៃការទំនាក់ទំនងសង្គមមាននិស្សិតចំនួន១៣នាក់ ដែលឆ្នាំទី២មានចំនួន៣នាក់។

លោករំពឹងថា ក្រោយពីនិស្សិតជំនាន់ទី១ នឹងបញ្ចប់ការសិក្សាក្នុងឆ្នាំនេះ ពួកគាត់នឹងអាចរកការងារបានធ្វើគ្រប់គ្នា ហើយកត្តានេះនឹងផ្តល់ផលវិជ្ជមានដល់និស្សិត ដែលកំពុងសិក្សានៅក្នុងសាលានាឆ្នាំបន្តបន្ទាប់ទៀត។

សាលាបច្ចេកទេស ដុនបូស្កូកែប ស្ថិតនៅក្នុងភូមិថ្មី ឃុំជ្រៃធំ ខេត្តកែប បានបង្កើតឡើងក្នុងឆ្នាំ២000 ដោយមានបង្រៀនវិជ្ជាជីវៈកាត់ដេរសម្រាប់ស្ត្រី ហើយក្នុងឆ្នាំ២០១១ សាលានេះបានបង្កើត ឲ្យមានជំនាញចំនួន ៦ ផ្នែករួមមានផ្នែកសិល្បៈ ផ្នែកកសិកម្ម ផ្នែកគ្រប់គ្រងការិយាល័យ ផ្នែកទំនាក់ទំនងសង្គម អគ្គិសនី និងផ្នែកសណ្ឋាគារ ៕

**ដោយកញ្ញា**



បន្ទប់សិក្សាផ្នែករចនារូបភាព ។រូបថតៈ KG


ពាក្យប្រឡងវគ្គ១ច្បាប់ តម្លៃ ៤000 រៀល

មជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈនិងបច្ចេកទេសដុនបូស្កូភ្នំពេញ

ត្រូវការជ្រើសរើសសិស្ស

ចាប់ទទួលពាក្យប្រឡង
10-13 សីហា 2015

ការជ្រើសរើស :

បេក្ខជនចាំបាច់ត្រូវឆ្លងកាត់ការសម្ភាសន៍ ពីគណៈគ្រប់គ្រងសាលា និង ការប្រឡងវិញ្ញាសារចំនួន ៤ មុខវិជ្ជាគឺ៖

១. វប្បធម៌ទូទៅ ២. អង់គ្លេស
៣. គណិតវិទ្យា ៤. គំនូរល្បងប្រាជ្ញា

ទូរស័ព្ទ: 023 23 14 64

website : www.donboscokhmer.org

កម្មវិធីបណ្តុះបណ្តាល

ជំនាញវិជ្ជាជីវៈ: C1, C2, C3

សិក្សាក្នុងសាលា ១៧ខែនិង ចុះកម្មសិក្សាតាមរោងចក្រ សហគ្រាស៣ខែ។

ជំនាញ ៖ - បោះពុម្ព
- ក្រឡឹង -ផ្សារ -ជួសជុលរថយន្ត

បច្ចេកទេសជាន់ខ្ពស់(អនុវិស្វករ)

សិក្សាក្នុងសាលា ២០ខែ និងចុះកម្មសិក្សាតាមរោងចក្រ សហគ្រាស៣ខែ។

ជំនាញ ៖ -ក្រឡឹង-ផ្សារ -ជួសជុលរថយន្ត
- អគ្គិសនី - អេឡិចត្រូនិច
- កុំព្យូទ័រ

# ព្រះសហគមន៍កាតូលិកសៀមរាបទទួលគ្រីស្តបរិស័ទថ្មី



*ពិធីជ្រមុជទឹកដល់គ្រីស្តបរិស័ទចំនួន១១នាក់។ រូបថត: ស្រីមាស*

ក្នុងពេល បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនេះ ព្រះសហគមន៍សៀមរាប បានទទួលបេក្ខជនចំនួន១១នាក់ឲ្យទទួលពិធីជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទកាតូលិក កាលពីថ្ងៃទី៥ មេសាកន្លងទៅ ដែលមានគ្រីស្តបរិស័ទចូលរួម ប្រមាណជាង ២០០នាក់។

លោក វីណាតូ ស្ទេផាននូស ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកតំបន់អង្គរ មានប្រសាសន៍ថា អគ្គសញ្ញាជ្រមុជទឹកបានធ្វើឲ្យអ្នកទាំង១១នាក់ ក្លាយជាមនុស្សថ្មី គឺទៅជាបុត្រធីតា របស់ព្រះជាម្ចាស់ ដោយដើរតាម ព្រះពន្លឺរបស់ព្រះគ្រីស្ត។ លោកបូជាចារ្យស្តេផានូស ក៏រំឭកដល់អស់បងប្អូន គ្រីស្តបរិស័ទដែលបានទទួលជ្រមុជទឹករួច ឲ្យយកចិត្តទុកដាក់ អង្វរព្រះជាម្ចាស់ក្នុងបុណ្យចម្លងនេះ ដើម្បីឲ្យបានទទួលជីវិតថ្មីពិតប្រាកដ និងទទួលសិរីរុងរឿងដោយអំណរសប្បាយ។

អ្នកស្រី ស៊ីប ឃីន មកព្រះសហគមន៍កាតូលិក ពាក់ស្នែងបានទទួលអគ្គសញ្ញាជ្រមុជទឹក ឲ្យដឹងថា ស្រីបានឃើញអំណរសប្បាយ ក្នុងព្រះសហគមន៍ធ្វើឲ្យអ្នកស្រីចាប់អារម្មណ៍ស្វែងយល់អំពីជំនឿ រហូតបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅក្នុងថ្ងៃនេះ។ អ្នកស្រីបន្ថែមថា មុនពេលដែលអ្នកស្រីបានមកទីនេះអ្នកស្រីទទួលរងនូវការតិះដៀល ពីសំណាក់អ្នកខាងយ៉ាងខ្លាំង ប៉ុន្តែទោះយ៉ាងនេះ អ្នកស្រីមិនចុះចាញ់ នៅតែបន្តជំនឿយ៉ាងរឹងមាំ និង សម្តែងធម៌មេត្តាករុណាដល់ពួកគេ គឺស្រឡាញ់ពួកគេ ដូចស្រឡាញ់ព្រះជាម្ចាស់ និងដូចស្រឡាញ់ខ្លួនឯងដែរ។

កម្មវិធីនេះបានធ្វើឡើង នៅព្រះសហគមន៍កាតូលិក ក្រុងសៀមរាប ដែលមានទីតាំង ស្ថិតនៅក្រុមទី១ សង្កាត់ស្លរក្រាម ខេត្តសៀមរាបដែលមានបេក្ខជន ទទួលពិធីជ្រមុជទឹកចំនួន១១នាក់ គឺមកពីពីរកន្លែង គឺមកពីព្រះសហគមន៍ពាក់ស្នែង និងព្រះសហគមន៍ក្រុងសៀមរាប។ ព្រះសហគមន៍កាតូលិកតំបន់អង្គរមាន៩ព្រះសហគមន៍ គឺសៀមរាប ចុងឃ្នាស តាអំ ព្រៃកទ័ល កំពង់ឃ្លាំង ចំណោម ប៉ោយប៉ែត ស្វាយស៊ីសុផុន និង ឧត្តរមានជ័យ៕

**ដោយស្រីមាស**

# ព្រះសហគមន៍តំបន់តាកែវមានគ្រីស្តបរិស័ទ៤៧នាក់បន្ថែម



*បេក្ខជនដែលទទួលពិធីជ្រមុជទឹកទាំង៤៧នាក់ ។រូបថត: សុធីរិទ្ធិ*

លោកអភិបាល អូលីវីយេ ដ្មឺតអឺស្ល៊េរ បានធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបេក្ខជនចំនួន៤៧នាក់នៅព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹម (ចំការទៀង) ស្ថិតនៅស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី៤ មេសា ដែលមានគ្រីស្តបរិស័ទ យុវជន និង អ្នកទទួលការស្វែងយល់ ប្រមាណជា ៤០០នាក់។

នៅក្នុងខណៈនោះផងដែរ លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ទៅកាន់បេក្ខជនទាំង ៤៧ នាក់ថា៖ កាលណាយើងទទួលអគ្គសញ្ញាជ្រមុជទឹក ដោយព្រះនាមព្រះបិតាព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ មានន័យថា យើងបានទទួលជីវិតថ្មី និងបានទទួលដង្ហើម ពីព្រះជាម្ចាស់ ទៅជាមនុស្សថ្មី មានន័យថា យើងលែងជាប់នឹងបាបកម្ម លែងជាប់អំពើបាបពីអតីតកាល ប៉ុន្តែយើងបានទទួលជីវិតថ្មីពីព្រះជាម្ចាស់ ព្រះគ្រីស្តជាពន្លឺ ព្រះគ្រីស្តជាព្រះជាម្ចាស់ណែនាំឲ្យម្នាក់ៗអាចសួរខ្លួនឯងថា ធ្វើដូចម្តេចអាចធ្វើជាសក្ខីភាព អំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដល់បងប្អូនឯទៀតៗ? ធ្វើដូចម្តេចឲ្យការប្រកាសដំណឹងល្អ អាចបម្រែបម្រួលពិភពលោកចេញពីភាពងងឹត ចូលទៅក្នុងពន្លឺ ចេញពីទុក្ខលំបាកចូលទៅក្នុងសេចក្តីសង្ឃឹម?

ប្អូនស្រី ស៊ូ ស្រីនិច ជាបេក្ខជនទទួលអគ្គសញ្ញាជ្រមុជទឹកបាននិយាយថានាងមានអំណរសប្បាយ ដែលបានទទួលទទួលជីវិតថ្មី ដែលជាអំណោយទានរបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់បានផ្តល់សេចក្តីស្រឡាញ់ និងណែនាំឲ្យមនុស្សទាំងអស់ ឲ្យមានមេត្តាករុណារវាងគ្នា និងគ្នា។ នាងបានបន្តថា៖ "ខ្ញុំមានជំនឿ និង ហ៊ានផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ ពេលខ្ញុំជួបទុក្ខលំបាក ខ្ញុំតែងតែអធិដ្ឋានទៅព្រះជាម្ចាស់ ពេលខ្ញុំឃើញអ្នកក្រីក្រ និង ចាស់ជរាហាក់ដូចជាពន្លឺព្រះជាម្ចាស់ ដែលព្រះអង្គប្រទានឲ្យខ្ញុំមានធម៌មេត្តាករុណា។ មិនតែប៉ុណ្ណោះព្រះជាម្ចាស់បានណែនាំខ្ញុំ ឲ្យចេះអត់ធ្មត់ និងអនុគ្រោះដល់អ្នកដទៃជានិច្ច" ។

បេក្ខជនទទួល អគ្គសញ្ញាជ្រមុជទឹក៤៧នាក់ក្នុងនោះមកពីព្រះសហគមន៍កាតូលិកសន្តី ម៉ារីញញឹមចំការទៀង ៣៩នាក់ និងមកពីព្រះសហគមន៍សន្តប៉ូល ៨ នាក់។ ព្រះសហគមន៍កាតូលិកសន្តី ម៉ារីញញឹម (ចំការទៀង) ចាប់កំណើត តាំងពីឆ្នាំ ១៩៩៧ ដែលមានគ្រីស្តបរិស័ទតែម្នាក់គត់ ប៉ុន្តែរហូតដល់ពេលបច្ចុប្បន្ននេះមានគ្រីស្តបរិស័ទ សរុបចំនួន ២៣៣នាក់។

**ដោយយុន សំអាត**


លោកបូជាចារ្យ ហ្វ្រង់ស្វ័សោវីយ៉េ ដឺម៉ុង

### ថ្ងៃអាទិត្យទី ៥ នៃបុណ្យចម្លង
### យហ ១៥,១-៨

នៅក្រោយព្រះយេស៊ូ ធ្វើពិធីជប់លៀង និង លាងជើងពួកសាវ័កនៅមុនគេចាប់ព្រះអង្គ។មុនពេលព្រះអង្គសោយទិវង្គតម្តងទៀត ព្រះអង្គអប់រំពួកសាវ័កតាមប្រស្នា ព្រះយេស៊ូមានបន្ទូលសម្រាប់ពួកគេថា ៖ *"ខ្ញុំហ្នឹងហើយ ជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ រីឯព្រះបិតាខ្ញុំជាម្ចាស់ចំការ" ១៥,១ខ* មួយទៀត *" ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក" ១៥,៥ក*។ព្រះយេស៊ូដាស់តឿនសាវ័ក ដើម្បីឲ្យពួកគេរួមគ្នាជាអង្គតែមួយក្នុងព្រះគ្រីស្ត ដូច្នេះព្រះបិតាថែរក្សាការពារពួកគេ។ ប្រសិនបើអ្នកណាចេញពីព្រះយេស៊ូ ព្រះអង្គមិនអាចសង្គ្រោះគេទេ ។

នៅសម័យបច្ចុប្បន្ន ព្រះយេស៊ូដែលជាព្រះពន្លឺ នៃបុណ្យចម្លងមានព្រះបន្ទូល សម្រាប់យើងដែរថា សូមធ្វើរួមគ្នាជាអង្គតែមួយក្នុងព្រះអង្គ ។ ដូច្នេះ ព្រះបិតាការពារថែរក្សាជីវិតរបស់យើង ។រួមគ្នាជាអង្គតែមួយក្នុងព្រះយេស៊ូគ្រីស្ត យើងបង្ហាញទឹកចិត្តមេត្តាករុណា នៃព្រះបិតាសម្រាប់ពិភពលោក។

### ថ្ងៃអាទិត្យទី ៦ នៃបុណ្យចម្លង
### យហ ១៥,៩-១៧

គម្ពីរនេះគឺ នៅក្រោយព្រះយេស៊ូធ្វើពិធីជប់លៀង និង លាងជើងពួកសាវ័កនៅមុនគេចាប់ព្រះអង្គ។

ទុក្ខលំបាក របស់ព្រះយេស៊ូចាប់ផ្តើម។ ព្រះគម្ពីរដែលយើងនឹងអាននៅសប្តាហ៍នេះ បន្តពីសប្តាហ៍មុន។ ក្រោយពេលដែលព្រះយេស៊ូ ធ្វើពិធីជប់លៀងជាមួយក្រុមសាវ័ក ព្រះអង្គមានចំណុចសំខាន់។ព្រះអង្គនិយាយច្បាស់ៗជាមួយពួកគេ ពីព្រោះព្រះអង្គយល់ថា ពួកសាវ័កខ្លាច។ ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា៖ *"វិន័យរបស់ខ្ញុំមានដូចតទៅនេះ គឺអ្នករាល់គ្នា ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ " (១៥, ១២)* មួយទៀត *"ខ្ញុំចាត់ទុកអ្នករាល់គ្នាជាមិត្តសម្លាញ់ "(១៥, ១៥ខ)*។ ឥឡូវនេះ ព្រះយេស៊ូមិនត្រូវការនិយាយ តាមពាក្យប្រស្នាទេ ព្រះអង្គនិយាយពិតប្រាកដ។ ខាងមុខសាវ័ក ព្រះអង្គបង្ហាញព្រះជាម្ចាស់ ព្រះអង្គជាសេចក្តីស្រឡាញ់។ ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះបិតា សា-វ័កជាបុត្រធីតារបស់ព្រះអង្គដែរ ។

នៅសម័យបច្ចុប្បន្ន តាមអគ្គសញ្ញាជ្រមុជទឹក ដូចសាវ័កយើងទៅជាបុត្រធីតារបស់ព្រះបិតា និងបងប្អូនរបស់ព្រះយេស៊ូ។ ពេលយើងស្រឡាញ់គ្នាទៅវិញទៅមកពិតប្រាកដ យើងបង្ហាញព្រះជាម្ចាស់ជាព្រះបិតា។

### ថ្ងៃអាទិត្យទី ៧ នៃបុណ្យចម្លង
### បុណ្យលើកតម្កើង ព្រះជាម្ចាស់លើកព្រះយេស៊ូឡើងលើ
### មក ១៦, ១៥-២០

នេះជាគម្ពីរចុងក្រោយរបស់លោកម៉ាកុស មុនព្រះជាម្ចាស់លើកព្រះយេស៊ូ ឡើងលើ។ លោកម៉ាកុសប្រាប់ថា សាក្សីឃើញព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ប៉ុន្តែសាវ័កមិនជឿពួកគេទេ។ ពេលសាវ័កជួបព្រះយេស៊ូ ព្រះអង្គនិយាយខ្លាំងៗ ហើយពួកគេទាំងអស់ ទៅជាសាវ័កពិតប្រាកដរបស់ព្រះអង្គ។ ដោយសារជំនឿពួកគេទទួលកម្លាំង និង អំណាចពិសេសពីព្រះយេស៊ូ ដើម្បីទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អ ដល់មនុស្សលោកទាំងអស់។ "អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ" (១៦, ១៦ក)។

នៅសម័យបច្ចុប្បន្ន ជាមួយព្រះយេស៊ូ យើងត្រូវហ៊ានបង្ហាញជំនឿលើព្រះអង្គ លើព្រះបិតា ។

### ថ្ងៃអាទិត្យទី ៨ នៃបុណ្យចម្លង
### បុណ្យលើកតម្កើងព្រះយេស៊ូចាត់ព្រះវិញ្ញាណយាងមក
### យហ១៥, ២៦-២៧ ; ១៦, ១២-១៥

នេះជាគម្ពីរ តាមលោកយ៉ូហាន នៅក្រោយព្រះយេស៊ូធ្វើពីធីជប់លៀង និងលាងជើងពួកសាវ័ក នៅមុនគេចាប់ព្រះអង្គ ។ ទុក្ខលំបាករបស់ព្រះយេស៊ូចាប់ផ្តើម ។ ពេលក្រោយព្រះយេស៊ូ ធ្វើពិធីជប់លៀងជាមួយក្រុមសាវ័ក ព្រះអង្គមានចំណុចសំខាន់ដោយនិយាយច្បាស់ៗ ជាមួយពួកគេ។ ប៉ុន្តែព្រះយេស៊ូយល់ថា សាវ័កខ្លាច ព្រះអង្គត្រូវលើកទឹចិត្តពួកគេមុនសោយព្រះទិវង្គត និងមានព្រះជន្មរស់ឡើងវិញ។ ជិតដល់ពេលហើយ ព្រះយេស៊ូអង្វរព្រះបិតាដើម្បីព្រះអង្គផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យមកសណ្ឋិតលើពួកសាវ័កឲ្យយល់ច្បាស់ពីការអប់រំរបស់ព្រះអង្គ គឺឲ្យព្រះវិញ្ញាណដឹកនាំពួកគេលើផ្លូវជាសេចក្តីពិត។ ព្រះវិញ្ញាណស្នាក់នៅជាមួយសាវ័ក ដោយព្រះនាមព្រះយេស៊ូ ។

នៅសម័យបច្ចុប្បន្ន តើយើងយល់ព្រមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ សណ្ឋិតលើយើង ដូចលើសាវ័កពីមុនដែរទេ? តើបងប្អូនយល់យ៉ាងម៉េច ពេលព្រះវិញ្ញាណសណ្ឋិតលើបងប្អូន ហើយនាំបងប្អូន ឲ្យស្គាល់ពីវត្តមានព្រះជាម្ចាស់ក្នុងជីវិតរស់នៅសព្វថ្ងៃ?

### ថ្ងៃអាទិត្យទី ៩ រដូវធម្មតា
### ថ្ងៃលើកតម្កើងព្រះត្រៃឯក
### មថ២៨, ១៦-២០

ក្នុងព្រះគម្ពីរ តាមលោកម៉ាថាយ នេះជាគម្ពីរចុងក្រោយ មុនព្រះជាម្ចាស់លើកព្រះយេស៊ូឡើងលើ។ លោកម៉ាថាយប្រាប់ថា ក្រោយបុណ្យចម្លង ក្រោយព្រះយេស៊ូ មានព្រះជន្មរស់ឡើងវិញ សាវ័កនាំគ្នាធ្វើដំណើរទៅស្រុកកាលីឡេ ។ នៅទីនោះ នៅលើភ្នំ ពួកសាវ័កជួបព្រះអង្គ។ ពួកគេទទួលបេសកកម្មមួយ។ អ្នកណាចង់ទៅជាសាវ័ករបស់ព្រះអង្គដែរ ពួកសាវ័កត្រូវធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ គេទទួលការអប់រំរបស់ព្រះយេស៊ូពីសាវ័ក។ ព្រះយេស៊ូបង្ហាញព្រះជាម្ចាស់ ជាព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះត្រៃឯក ។

នៅសម័យបច្ចុប្បន្ន តាំងពីយើងបាន ទទួលអគ្គសញ្ញាជ្រមុជទឹកយើងទៅជាសាវ័ករបស់ព្រះយេស៊ូ។ តើយើងបន្តធ្វើសាវ័ករបស់ព្រះអង្គយ៉ាងម៉េច? តើយើងអធិដ្ឋានយ៉ាងម៉េច? ប៉ុន្មានដងក្នុងមួយថ្ងៃ? តើយើងខ្ញុំស្វែងយល់ព្រះជាម្ចាស់ ជាព្រះត្រៃ-ឯកយ៉ាងម៉េច? តើក្នុងព្រះសហគមន៍របស់យើង យើងជួយគ្នាទៅវិញទៅមកប៉ុណ្ណានិងធ្វើយ៉ាងដូចម្តេច?

# ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី



ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើជាផ្លូវការ កាលពីថ្ងៃទី៩ ខែមករា ២០១៥។ អ្នកនាំសារនឹងយកច្បាប់នេះមកជម្រាបជូនអ្នកអាន នូវចំណុចមួយចំនួននៃច្បាប់។

**មាត្រា១១៖**

- ភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺពណ៌លឿង ជាសញ្ញាឲ្យប្រុងប្រយ័ត្ន ត្រៀមឈប់ ពន្លឺពណ៌បៃតងជាសញ្ញាអនុញ្ញាតឲ្យយានជំនិះចេញដំណើរ ពន្លឺពណ៌ក្រហម ជាសញ្ញាឃាត់ឲ្យឈប់។

- ភ្លើងសញ្ញាពណ៌ក្រហម គឺជាសញ្ញាឃាត់ឲ្យឈប់ អ្នកបើកបរត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូស ជាប់ពណ៌ស កាត់ទទឹងទ្រូងផ្លូវ ឬមុខគំនូសថ្មើរជើងឆ្លងកាត់។ បើគ្មានឧបសគ្គនៅខាងមុខ យានជំនិះខាងស្តាំបំផុតអាចបត់ស្តាំបានដោយប្រុងប្រយ័ត្ន លើកលែងតែមានសញ្ញាព្រួញពណ៌ក្រហមហាមបត់ស្តាំ៕

# ■ រូបថតសកម្មភាពព្រះសហគមន៍ទាំងបីភូមិភាគ

## សកម្មភាពចូលឆ្នាំខ្មែរនៅព្រះសហគមន៍ប៉ៃលិន
















លោកអភិបាលថតរូបអនុស្សាវរីយ៍ជាមួយនឹងលោកបូជាចារ្យ???។រូបថតៈ វ៉ាន់ សម្បត្តិ



ចូលឆ្នាំថ្មីនៅសន្តប៉ូល



បោះដុំរំកាយឫទ្ធិនៅជំគិរី



បុណ្យចម្លងនៅចំការទៀង

រូបពីមណ្ឌលគិរី (ស្រីម៉ាច)



បុណ្យចម្លងនៅគងណយ

អេម៉ាណូអែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | | |
|---|---|---|
| ភ្នំពេញ | : **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពត | : **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

**កម្មវិធីវិទ្យុ**

**" ខ្ញុំត្រូវការអ្នក "**

**ជាកម្មវិធីសម្រាប់យុវជន**

ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក